# ទស្សនាវដ្តី

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
THE NGO FORUM ON CAMBODIA

ឆ្នាំទី០៤ លេខទី០៦ ខែកក្កដា ឆ្នាំ២០០៧











ទស្សនាវដ្តី

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល
ស្តីពីកម្ពុជា

លេខ០៩ ខែកក្កដា ឆ្នាំ២០០៧

## មាតិកា

ពិធីផ្សព្វផ្សាយសេចក្តីថ្លែងការណ៍.... ..................................ទំព័រទី ១

រកឃើញការដឹកជញ្ជូនឈើប្រណិត... ..................................ទំព័រទី ២

បទពិសោធនីការងារពង្រឹងសិទ្ធិអំណាចស្ត្រី....................ទំព័រទី ៣

សេចក្តីថ្លែងការណ៍សម្ព័ន្ធទន្លេកម្ពុជា... ..................................ទំព័រទី ៦

វិវាទដីធ្លី និងដីព្រៃនៅស្រុក........... ..................................ទំព័រទី ៨

ការយល់ដឹង និងការពារបរិស្ថាន.... ..............................ទំព័រទី ១០

ហេតុអ្វីបានជាចាំបាច់ត្រូវមានតួនាទីស្ត្រី ..............................ទំព័រទី ១១

កិច្ចប្រជុំរវាងរដ្ឋបាលព្រៃឈើ និង.... ..............................ទំព័រទី ១២

វគ្គបណ្តុះបណ្តាលស្តីពីការដោះស្រាយ.. ..............................ទំព័រទី ១៤

ពពុះទឹកមានជាតិពុល................. ......................ទំព័រទី ១៥

មជ្ឈមណ្ឌលព័ត៌មានដីធ្លី.............. ...............................ទំព័រទី១៦

លទ្ធផលជាផ្លែផ្កាដែលទទួលពីវេទិកា ...............................ទំព័រទី១៦

បញ្ហាថ្នាំកសិកម្ម និងជីវភាពកសិករ ...............................ទំព័រទី១៦

---

គណៈកម្មាធិការត្រួតពិនិត្យ

-លោក ឈិត សំអាត

-លោក ទី សន

-លោក ឯក ស៊ីដេន

-លោក យុន ប៊ុណ្ណាត

-លោក សេង សុខឡុង

## អារម្ភកថា

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) មានវត្តមានដើម្បីចែករំលែកព័ត៌មាន ពិភាក្សា និងធ្វើការតស៊ូមតិលើបញ្ហាអាទិភាពនានាដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍នៅកម្ពុជា។ NGO Forum ចង់ឃើញប្រទេសកម្ពុជាមានប្រជាពលរដ្ឋរបស់ខ្លួនដែលជ្រួតជ្រាបអំពីព័ត៌មានទាំងឡាយ ព្រមទាំងបានទទួលការផ្តល់អំណាចឱ្យចូលរួមក្នុងសង្គមស៊ីវិលដ៏ត្រចះត្រចង់ និងរឹងប៉ឹងមួយដើម្បីផ្តល់ផលប្រយោជន៍ដល់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា។ NGO Forum ជំរុញអង្គការសមាជិករបស់ខ្លួន និងអង្គការទាំងអស់ដទៃទៀតឱ្យធ្វើការរួមគ្នាដើម្បីនិយាយពាក្យជាធ្លុងមួយដ៏មានឥទ្ធិពលដើម្បីការពារប្រយោជន៍ និងសិទ្ធិរបស់ជនក្រីក្រ។ NGO Forum គឺជាអង្គការសមាជិកភាពមួយសំរាប់ទាំងអង្គការក្នុងស្រុកនិងអន្តរជាតិទាំងឡាយ ។ ជោគជ័យរបស់ NGO Forum គឺពឹងផ្អែកទាំងស្រុងទៅលើការខិតខំរបស់អង្គការសមាជិក។ ទស្សនាវដ្តីនេះមានបំណងចងក្រងសមិទ្ធផលនានារបស់អង្គការសមាជិកទាំងឡាយក៏ដូចជា ដើម្បីផ្តល់ព័ត៌មានថែមទៀតទាក់ទិននឹង ***ការងារអភិវឌ្ឍន៍ បរិស្ថាន ដីធ្លី និងការចិញ្ចឹមជីវិត*** និង***បញ្ហាយេនឌ័រ*** ដល់អ្នកអានទូទៅដោយរាប់បញ្ចូលប្រជាពលរដ្ឋនៅក្នុងខេត្តដាច់ស្រយាលនានាផងដែរ ។ ទស្សនាវដ្តីនេះមានគោលបំណងពិសេសក្នុងការ:

• លើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តការរវាងអង្គការសមាជិកទាំងអស់របស់ NGO Forum ។

• បង្កើនការយល់ដឹងដល់ពលរដ្ឋកម្ពុជា អំពីបញ្ហានានានៃការអភិវឌ្ឍន៍កំពុងតែកើតឡើងដែលអាចប៉ះពាល់ដល់ជីវភាពរបស់ពួកគេ ។ និង

• លើកកំពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការបង្កើត និងការកែលំអគោលនយោបាយដែលអាចប៉ះពាល់ដល់ជីវភាពរបស់ពួកគេ ។

NGO Forum សូមស្វាគមន៍នូវការចូលរួមចំណែកផ្តល់អត្ថបទសំរាប់ទស្សនាវដ្តីនេះ និងសូមស្វាគមន៍រាល់មតិរិះគន់ដើម្បីកែលំអនានា។

## PREFACE

The NGO Forum exists for information sharing, debate and advocacy on priority issues affecting Cambodia's Development. The NGO Forum wants to see Cambodia will have a well-informed and empowered population participating in a strong and vibrant civil society, to the benefit of poor and vulnerable people in Cambodia. The NGO Forum approaches to all its member organizations and active not-member organizations for working together to collate a strong one voice for protecting the underlying benefits of the poor. The NGO Forum is a membership organization for local and international NGOs, which owes its success to the efforts of its members. In the future, this magazine intends to compile the achievements of member organizations as well as to provide more information regarding ***development***, ***environment***, ***land*** and ***livelihoods***, and ***gender*** issues to a broader audience, including to people in remote provinces. Specific objectives of the magazine are as follows:

• To encourage collaboration among the member organizations of the NGO Forum;

• To increase the awareness of Cambodian people about contemporary development issues which affect their lives; and

• To promote people's participation in policy developments and reforms that may affect their lives.

The NGO Forum on Cambodia welcomes contributive articles from member organizations and any constructive criticism for improvement.

# ពិធីផ្សព្វផ្សាយសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលចំពោះវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០០៧

មិនខុសពីឆ្នាំមុនៗទេ ដើម្បីចូលរួមចំណែកនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (ដែលកាលពីមុនហៅថាកិច្ចប្រជុំពិគ្រោះយោបល់) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាសហការជាមួយគណៈកម្មាធិការសហប្រតិបត្តិដើម្បីកម្ពុជា និងអង្គការម៉េឌីខាំ បានបោះពុម្ព **"សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលចំពោះវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០០៧"** និងឯកសារគោលរបស់សេចក្តីថ្លែងការណ៍ហៅថា **"ឯកសារស្តីពីគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីការអភិវឌ្ឍន៍របស់កម្ពុជាក្នុងឆ្នាំ២០០៦"** ។ ឯកសារទាំងពីរនេះគឺជាលទ្ធផលនៃការខិតខំប្រឹងប្រែងរួមមួយដោយមានការរួមចំណែកពីសហគមន៍អង្គការមិនមែនរដ្ឋាភិបាលនៅទូទាំងប្រទេសកម្ពុជាតាមរយៈអង្គការបណ្តាញតាមវិស័យការងាររបស់ពួកគេ ។

ឯកសារបោះពុម្ពទាំងពីរនេះបានធ្វើការផ្សព្វផ្សាយកាលពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៧ នៅឯសាលប្រជុំរបស់អង្គការទស្សនៈពិភពលោកក្រុងភ្នំពេញ ។ មានអ្នកតំណាងមកពីបណ្តាសមាគមន៍ អង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិ និងមកពីស្ថាប័នម្ចាស់ជំនួយប្រមាណចំនួនជាង ២៥០នាក់ បានចូលរួមនៅក្នុង ពិធីផ្សព្វផ្សាយនេះ ។ ក្រោយពីពិធីផ្សព្វផ្សាយនេះ មានរៀបចំធ្វើសន្និសីទសារព័ត៌មានរយៈពេល ៣០នាទី ។ តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលជា វាគ្មិននៅក្នុងសន្និសីទសារព័ត៌មាននេះ មានចំនួនបីរូបគឺ ១) លោក **ឈិត សំអាត** នាយកប្រតិបត្តិរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ២) លោក **ស៊ិន សូមុនី** នាយកប្រតិបត្តិអង្គការម៉េឌីខាំ និង ៣) លោក **សុខ សំអឿន** នាយកប្រតិបត្តិរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ។

ឯកសារទាំងពីរនេះមានគោលបំណងរួមចំណែកក្នុងការពិភាក្សាស្តីពីគោលនយោបាយនៅតាមវេទិកានានាជាមួយរាជរដ្ឋាភិបាល និងម្ចាស់ជំនួយនៅកម្ពុជា ។ ឯកសារស្តីពីគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាល រួមមានវិស័យទាំង ២៣ មានបំណងចូលរួមផ្តល់នូវយោបល់ក្នុងន័យស្ថាបនាកែលំអទៅលើវឌ្ឍនភាពរបស់ការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ និងការអនុវត្តន៍សូចនាករតាមដានរួមក្នុងឆ្នាំ២០០៦ ។ ឯកសារទាំងពីរនេះមាននៅលើគេហទំព័ររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា តាមរយៈអាស័យដ្ឋាន www.ngoforum.org.kh/Development/Docs/doc.htm ។

ដើម្បីជូនដំណឹងសំរាប់ការពិភាក្សានៅឯវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ឯកសារសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ទៅកាន់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា បានកំណត់ជ្រើសរើសយកនូវបញ្ហាជាអាទិភាពសំខាន់ៗចំនួនបីគឺ ១) បញ្ហាដីធ្លីកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ ២) ការអភិវឌ្ឍន៍ធនធានមនុស្ស និង ៣) អភិបាលកិច្ចល្អ ដែលមានសក្តានុពលយ៉ាងខ្លាំងក្នុងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ និងងាយរងគ្រោះនៅកម្ពុជារាប់លាននាក់ ប្រសិនបើមានការអនុវត្តន៍នូវកម្មវិធីកំណែទម្រង់ និងគោលនយោបាយអោយបានសមស្រប ។

តំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួនបីរូបត្រូវបានជ្រើសរើសអោយធ្វើជាតំណាងសហគមន៍អង្គការមិនមែនរដ្ឋាភិបាលនៅឯវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានៅថ្ងៃទី១៩-២០ ខែមិថុនា ឆ្នាំ២០០៧ ។ តំណាងទាំងបីរូបនោះរួមមានៈ ១) លោក **ឈិត សំអាត** នាយកប្រតិបត្តិរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល តំណាងបញ្ហាដីធ្លីកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ ២) លោកស្រី **ចាន់ ធារី** នាយិកាសម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ (RACHA) តំណាងបញ្ហាការអភិវឌ្ឍន៍ធនធានមនុស្ស និង ៣) លោក **សុខ សំអឿន** នាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាតំណាងបញ្ហាអភិបាលកិច្ចល្អ ។

ពិធីផ្សព្វផ្សាយដែលមានរយៈពេលកន្លះថ្ងៃនេះរៀបចំឡើងដោយមានការសហការរៀបចំដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាអង្គការផែកកម្ពុជា និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។

*អត្ថបទដោយ លោក **ង៉ោ សុផាត** មន្ត្រីគំរោងគោលនយោបាយអភិវឌ្ឍន៍នៃវេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។*




អ្នកចូលរួមនៅក្នុងពិធីផ្សព្វផ្ស... ...ចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលចំពោះវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា



# រកឃើញការដឹកជញ្ជូនឈើប្រណីត និង រោងសិប្បកម្មគ្រឿងសង្ហារឹមនៅជ្រោយចង្វារាជធានីភ្នំពេញ

នៅរសៀលថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧ អង្គការវេទិការនៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានទទួលព័ត៌មានពីអង្គការសហគមន៍ព្រៃឈើអន្តរជាតិ ស្តីពីការដឹកឈើដោយខុសច្បាប់តាមឡានក្រុងមកពីខេត្តក្រចេះ ព្រះវិហារ និងឧត្តមានជ័យ ។ ក្រោយពីបានទទួលព័ត៌មានហើយក្រុមការងារបានពិភាក្សាគ្នាដើម្បីរកយុទ្ធសាស្ត្រ សកម្មភាព និងព័ត៌មានសំខាន់ៗដែលជាតម្រូវការចំបាច់របស់យើងដើម្បីធ្វើការចុះអង្កេតជាក់ស្តែង ។

## ព័ត៌មាននៅកន្លែងកើតហេតុ:

នៅថ្ងៃបន្ទាប់ក្រុមការងារដែលក្នុងនោះ មកពីក្រុមព័ត៌មាន ដោយមានការសំរបសំរួលពីមន្ត្រីស៊ើបអង្កេតរបស់វេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានចុះដល់ទីកន្លែងជាក់ស្តែងដោយបានធ្វើការសាកសួរព័ត៌មានផ្សេងៗជាមួយម្ចាស់សិប្បកម្ម និងកម្មករទាក់ទងទៅនឹងការដឹកឈើ និងការកែច្នៃឈើ ។

ក្រុមការងារក៏បានធ្វើការសាកសួរប្រជាពលរដ្ឋដែលរស់នៅក្បែរចំណតឡានក្រុងជ្រោយចង្វា ហើយយើងក៏ទទួលបានព័ត៌មានថា នៅមិនឆ្ងាយពីស្ពានជ្រោយចង្វាមានផ្ទះចំនួន ៣ ដែលជារោងកែច្នៃឈើធ្វើជាគ្រឿងសង្ហារឹម ។ ម្ចាស់រោងសិប្បកម្មនិយាយថាឈើប្រណីតទាំងអស់នេះត្រូវបានដឹកជញ្ជូនមកពីបណ្តាខេត្តនានាដូចជា ក្រចេះ ព្រះវិហារ និងឧត្តមានជ័យ ។ ម្ចាស់រោងសិប្បកម្មមិនបានលើកឡើងថា ការប្រមូលឈើ និងការដឹកជញ្ជូនឈើប្រណីតនេះប្រព្រឹត្តទៅដោយស្របច្បាប់ទេ ។ ប៉ុន្តែក្រុមការងារបានរកឃើញថា ឈើប្រណីតទាំងអស់នេះ ត្រូវបានដឹកជញ្ជូនតាមរយៈឡានក្រុង និងឡានធំៗផ្សេងទៀតដោយលាក់កំបាំង ។ ម្ចាស់រោងសិប្បកម្មក៏បាននិយាយផងដែរ គាត់បានប្រកបមុខរបរនេះជាង ១៨ឆ្នាំមកហើយ ព្រមទាំងស្គាល់អ្នករកស៊ីមុខរបរនេះជាច្រើននាក់ផងដែរ ។

ក្រុមការងារបានរកឃើញនូវគំនរឈើប្រណីតដែលទើបតែដឹកជញ្ជូនមកថ្មីៗនេះ ។ ឈើនេះត្រូវបានដឹកមកពីខេត្តក្រចេះ និងខេត្តផ្សេងទៀតតាមរយៈឡានធំមួយ ។ ម្ចាស់រោងសិប្បកម្មក៏បានប្រាប់ក្រុមការងារពីឈ្មោះរបស់គាត់ និងម្ចាស់ឡានដែលបានដឹកជញ្ជូនឈើអោយគាត់ផងដែរ ពីខេត្តក្រចេះ ព្រះវិហារ និងឧត្តមានជ័យ ។

## សកម្មភាពដែលបានធ្វើបន្ទាប់ពីការអង្កេត:

ក្រោយពីក្រុមការងារបានធ្វើការអង្កេតករណីរួចកម្មវិធីជីផ្ទី និងជីវភាពរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលបានធ្វើលិខិតមួយជូនឯកឧត្តមប្រធានរដ្ឋបាលព្រៃឈើភ្ជាប់ជាមួយនូវរូបភាពដែលក្រុមការងារបានថតដើម្បីជូនឯកឧត្តមជ្រាប និងចំណាត់ការតាមការគួរ ។ ទោះបីជាករណីនោះត្រូវបានបញ្ជូនទៅរដ្ឋបាលព្រៃឈើក៏ដោយ ក៏ក្រុមការងារបានឯកភាពថា នឹងយកករណីនេះមកធ្វើការផ្សព្វផ្សាយនៅឯកិច្ចប្រជុំបណ្តាញព្រៃឈើ និងចំការឈើដាំព្រមទាំងតាមដានយកចិត្តទុកដាក់លើវិធានការរបស់រដ្ឋបាលព្រៃឈើក្នុងការចាត់នូវវិធានការណាមួយសមស្របជាពិសេសការអនុវត្តន៍ច្បាប់ព្រៃឈើដែលសភាជាតិបានអនុម័ត ។

ជាក់ស្តែងយើងបានមើលឃើញយ៉ាងច្បាស់ថា សកម្មភាពបំផ្លិចបំផ្លាញព្រៃឈើក្នុងពេលបច្ចុប្បន្ននេះ បានគំរាមកំហែងយ៉ាងខ្លាំងក្លាដល់ការគ្រប់គ្រងធានធានព្រៃឈើអោយមាននិរន្តភាព ហើយបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ។ ជាពិសេសសហគមន៍ដែលរស់ដោយពឹងអាស្រ័យលើការដកហូតប្រមូលផល និងអនុផលព្រៃឈើជាដើម ។

អនុសាសន៍លើកឡើងថា ការលុបបំបាត់អំពើពុករលួយលើវិស័យព្រៃឈើគឺជាកិច្ចការអាទិភាពមួយ ហើយទាមទារកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សហគមន៍មូលដ្ឋាន ម្ចាស់ជំនួយ និងរាជរដ្ឋាភិបាល ។

*អត្ថបទដោយបណ្តាញគាំរោងព្រៃឈើ និងចំការឈើដាំវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។*



សកម្មភាពផលិតគ្រឿងសង្ហារឹម នៅជ្រោយចង្វា ក្រុងភ្នំពេញ

# បទពិសោធន៍ការងារពង្រឹងសិទ្ធិអំណាចស្ត្រី និងការអភិវឌ្ឍន៍សេដ្ឋកិច្ច

កាលពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ បណ្តាញវេទិកាយេនឌ័របានធ្វើទៅទស្សនៈកិច្ចសិក្សានៅខេត្តពីរ គឺខេត្តកំពង់ចាម និងខេត្តសៀមរាប ក្នុងគោលបំណងបង្កើនការយល់ដឹងអំពីការពង្រឹងសិទ្ធិអំណាចស្ត្រីនៅថ្នាក់សហគមន៍ និងសកម្មភាពលើកកំពស់ស្ត្រី និងការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលពាក់ព័ន្ធនឹងការរកប្រាក់ចំណូលរបស់អង្គការដែលជាសមាជិកបណ្តាញយេនឌ័រ មានអង្គការ CEDAC នៅស្រុកបាធាយ ខេត្តកំពង់ចាម និងអង្គការបន្ទាយស្រី នៅស្រុកអង្គធំ ខេត្តសៀមរាប ។

តាមរយៈទស្សនៈកិច្ចសិក្សា និងការពិភាក្សាស្វែងយល់ជាមួយគណៈកម្មការភូមិ ក្រុមទស្សនៈកិច្ចសិក្សាទទួលបាននូវបទពិសោធន៍ថ្មីៗពាក់ព័ន្ធទៅនឹងការពង្រឹងសិទ្ធិអំណាចស្ត្រី និងស្ត្រីក្នុងភាពអ្នកដឹកនាំក្នុងការងារអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ និងសហគមន៍ ។

## បទពិសោធន៍ដែលទទួលបានមានដូចជា

### ការពង្រឹងគណៈកម្មការភូមិ

- គណៈកម្មការភូមិមានការប្រជុំពិភាក្សាគ្នាជាប្រចាំ ដើម្បីចែករំលែកបទពិសោធន៍ និងផ្សព្វផ្សាយព័ត៌មានអោយគ្នាទៅវិញទៅមក បង្កើនទំនាក់ទំនងគ្នា និងកសាងភាពជឿជាក់ដល់គណៈកម្មការនីមួយៗ ។
- ការជួបពិភាក្សាស្វែងយល់ជាមួយគណៈកម្មការភូមិ គណៈកម្មការមានផែនការសកម្មភាពការងារប្រចាំឆ្នាំ ប្រចាំត្រីមាស ប្រចាំខែ និងមានរបាយការណ៍វឌ្ឍនៈភាព ។
- មានការជំរុញលើកទឹកចិត្តស្ត្រីចូលរួមជាសមាជិកគណៈកម្មការ និងនៅគ្រប់សកម្មភាពអភិវឌ្ឍន៍ភូមិ ។
- មានសមាជិកគណៈកម្មការជាស្ត្រី និងមានការទទួលខុសត្រូវការងារខ្ពស់ ។
- មានការគាំទ្រសកម្មភាព បង្កើតក្រុមស្ត្រីពីអាជ្ញាធរភូមិ ឃុំ និងគ្រួសារនៅគ្រប់កម្មវិធី ។
- មានការលើកទឹកចិត្តពីបុរសជាប្តី អោយភរិយាចូលរួមជាសមាជិកគណៈកម្មការ ។

### អំពីកម្មវិធី

- មានការរៀបចំវេទិកាស្ត្រីដើម្បីអោយស្ត្រីមានភាពក្លាហាន ហ៊ាននិយាយ ហ៊ានសួរ និងផ្តល់ឱកាសដល់ស្ត្រី ពិភាក្សាគ្នាអំពីយេនឌ័រ បញ្ហារបស់ស្ត្រី ដូចជា អំពើហិង្សា ការជួញដូរស្ត្រី ការចាប់រំលោភ និងសកម្មភាពផ្សព្វផ្សាយផ្សេងៗ ។
- បំផុសអោយមានសកម្មភាពចូលរួមរបស់អ្នកភូមិ អាចារ្យ និងព្រះសង្ឃក្នុងការងារអភិវឌ្ឍន៍សង្គម ។ ឧទាហរណ៍: ការដង្ហែរកូនឈើយកទៅដាំក្នុងវត្ត និងសកម្មភាពដាំកូនឈើរបស់អ្នកភូមិនៅតាមទីសាធារណៈ និងតាមផ្ទះ ( អង្គការ CEDAC ) ។
- មានកម្មវិធីឥណទានដែលកើតមានឡើងពីការសន្សំប្រាក់របស់សមាជិកដែលអាចកាត់បន្ថយការខ្ចីបុលពីក្រៅភូមិដែលមានអត្រាការប្រាក់ខ្ពស់ ។ មានករណីពិសេសមួយទៀតគឺ សមាជិកក្នុងក្រុមអាចខ្ចីប្រាក់បានភ្លាមៗពីគណៈកម្មការ ដើម្បីយកទៅចំណាយលើភាពអាសន្នដូចជា ព្យាបាលជម្ងឺ និងមានផ្តល់ឥណទានដល់ក្រុមក្រីក្រដោយមិនយកការប្រាក់ ។
- មានការលើកទឹកចិត្ត និងគាំទ្រស្ត្រីដឹកនាំសហគមន៍អោយឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ និងបានជាប់ជាសមាជិក ។
- មានកិច្ចសហការល្អជាមួយអង្គការដៃគូ ( អង្គការវ៉ាក់ អាដហុក ប៉ាដេក និង WFP) ក្នុងការជួយបណ្តុះបណ្តាលដល់ក្រុមស្ត្រីលើជំនាញផ្សេងៗ ។
- មានភាពក្លាហានហ៊ានធ្វើការតស៊ូមតិដីធ្លី និងកសាងផ្លូវលំចូលភូមិ ។

### មេរៀនបទពិសោធន៍

- សមាជិកសហគមន៍ទាំងអស់មានភាពជាម្ចាស់លើគំរោងកម្មវិធី និងចេះទំនាក់ទំនងជាមួយអង្គការនានាដើម្បីគាំទ្រជំនាញបច្ចេកទេសផ្សេងៗ ។
- អាចយកជំនាញដែលបានរៀនសូត្រពីអង្គការទៅធ្វើជាមុខរបរដើម្បីរកប្រាក់ចំណូល ។
- មានកម្មវិធីឥណទានដែលកើតពីការសន្សំប្រាក់របស់សមាជិកសហគមន៍ ។
- សហគមន៍មានការយល់ដឹង និងអនុវត្តការថែទាំសុខភាព និងអនាម័យប្រសើរជាងមុន ។
- សហគមន៍មានការយល់ដឹងពីយេនឌ័រ និងសារៈសំខាន់នៃការចូលរួមរបស់ស្ត្រី ។

*អត្ថបទដោយ លោកស្រី **ធី និចល** មន្ត្រីគំរោងយេនឌ័រនៃវេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។*



ការជួបពិភាក្សាស្វែងយល់ជាមួយគណៈកម្មការភូមិ





ក្រុមតំបាញស្ត្រីនៅវិទ្យាស្ថានវាយនភណ្ឌប្រពៃណីខ្មែរ

ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៧

## សម្ព័ន្ធទន្លេកម្ពុជា

# សេចក្តីថ្លែងការណ៍
# ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧
# ភ្នំពេញ, កម្ពុជា

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា-វៀតណាមមិនបានអនុញ្ញាតសហគមន៍ ដែលរងគ្រោះឱ្យចូលរួម កិច្ចប្រជុំពិនិត្យមើលរបាយការណ៍ វាយតម្លៃផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីគំរោងអភិវឌ្ឍន៍វារីអគ្គីសនីនៅតាមដងទន្លេសេសានដែលបានរៀបចំធ្វើកាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៧ នៅសណ្ឋាគារភ្នំពេញ នោះទេ។

សម្ព័ន្ធភាពទន្លេកម្ពុជា សូមអំពាវនាវឱ្យមានដំណើរការពិគ្រោះយោបល់ត្រឹមត្រូវក្នុងការពិនិត្យមើល របាយការណ៍។

ភ្នំពេញ - គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងគណៈកម្មាធិការជាតិទន្លេមេគង្គវៀតណាមបានរៀបចំកិច្ចប្រជុំកាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៧ នៅសណ្ឋាគារភ្នំពេញ ដើម្បីពិនិត្យមើលហេតុប៉ះពាល់បរិស្ថាន នៃការអភិវឌ្ឍន៍វារីអគ្គីសនីនៅតាមដងទន្លេសេសានដែលជាប្រភពទឹកដ៏ធំធេងហូរចាក់ទៅក្នុងទន្លេមេគង្គដោយឆ្លងកាត់ប្រទេសកម្ពុជា និងវៀតណាម។

សមាជិកខ្លះនៃសម្ព័ន្ធភាពទន្លេកម្ពុជាត្រូវបានអញ្ជើញ ប៉ុន្តែមិនអាចចូលរួមក្នុងកិច្ចប្រជុំ ដោយសារសហគមន៍ដែលរងគ្រោះពីការសាងសង់ទំនប់វារីអគ្គីសនីនៅតំបន់ភូមិភាគឥសាននៃប្រទេសកម្ពុជាមិនត្រូវបានអនុញ្ញាតឱ្យចូលរួមឡើយ ហើយរបាយការណ៍ប្រមាណ ១៨៧ទំព័រ ត្រូវបានចែកជូនរយៈពេលមួយសប្តាហ៍គត់ មុនពេលកិច្ចប្រជុំដែលមិនមានពេលគ្រប់គ្រាន់សម្រាប់បកប្រែ ឬចែកជូនព័ត៌មានឱ្យបានទូលំទូលាយក្នុងប្រទេសកម្ពុជា។

ការសាងសង់ទំនប់វារីអគ្គីសនីនៅតាមដងទន្លេសេសាន ដែលជាប្រភពទឹកដ៏ធំធេងហូរចាក់ទៅក្នុងទន្លេមេគង្គ ដោយឆ្លងកាត់ប្រទេសកម្ពុជា និងវៀតណាម ដែលធ្វើឱ្យប៉ះពាល់ប្រជាពលរដ្ឋរាប់រយពាន់នាក់នៅតំបន់ ភូមិភាគឥសាននៃប្រទេសកម្ពុជា ដែលពួកគាត់ពឹងផ្អែកលើទន្លេសម្រាប់ការផ្គត់ផ្គង់ជីវិតដូចជាការនេសាទ និងប្រើប្រាស់ទឹក ជាដើម។

សម្ព័ន្ធទន្លេកម្ពុជាមានការសោកស្តាយចំពោះគណៈកម្មាធិការជាតិទន្លេមេគង្គដែលមិនបានអញ្ជើញសហគមន៍ដែលរងគ្រោះឱ្យចូលរួមក្នុងកិច្ចប្រជុំ និងសូមអំពាវនាវដល់គណៈកម្មាធិការជាតិទន្លេមេគង្គទាំងពីរ និងម្ចាស់ជំនួយអន្តរជាតិ ដើម្បីរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈសមស្រប ដោយទទួលស្គាល់យ៉ាងពេញលេញចំពោះសិទ្ធិប្រជាពលរដ្ឋដែលរងគ្រោះដោយការអភិវឌ្ឍន៍វារីអគ្គីសនី ព្រមទាំងគោរពនូវបទពិសោធន៍ល្អៗខាងអន្តរជាតិក្នុងការពិគ្រោះយោបល់ជាសាធារណៈ។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានរៀបចំឡើងដោយទីប្រឹក្សា ណ័រឌិក ហៃដ្រូ (Nordic hydro) សម្រាប់អគ្គីសនីវៀតណាម ស្វីកូ-ហ្គ្រោន (SWECO Groner) និងវិទ្យាស្ថានណ័រវេសសម្រាប់ស្រាវជ្រាវអំពីទឹកដែលបានមកសិក្សាប្រាំមួយឆ្នាំ ក្រោយពីការសាងសង់ទំនប់ដ៏ធំមហិមានៅតាមដងទន្លេសេសាន ដែលបណ្តាលឱ្យមនុស្សប្រមាណ ៣០នាក់ស្លាប់ និងទ្រព្យសម្បត្តិមួយចំនួនត្រូវបាត់បង់ដូចជាទូក ឧបករណ៍នេសាទ និងសត្វពាហនៈ។ គ្មានវិធានការសម្រាប់សំណង ឬការសម្រាលត្រូវបានផ្តល់ឱ្យឡើយ ក្រៅពីសំណើសុំដដែលៗពីសហគមន៍ ពីមន្ត្រីរដ្ឋាភិបាល និងពីអង្គការមិនមែនរដ្ឋាភិបាលនានាច្រើនដងក្តី។

បទពិសោធន៍ល្អខាងអន្តរជាតិត្រូវការថា ការវាយតម្លៃផលប៉ះពាល់បរិស្ថានត្រូវតែបំពេញមុនអនុម័ត គំរោងដើម្បីជួយដល់អ្នកធ្វើការសម្រេចចិត្ត អ្នកផ្តល់ហិរញ្ញវត្ថុ និងការស្ទាបស្ទង់មើលជាសាធារណៈលើស្ថានភាពទូទៅរបស់គំរោង។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីនេះ របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន ទន្លេសេសានបានធ្វើឡើងបីឆ្នាំក្រោយពីអគ្គីសនីវៀតណាមចាប់ផ្តើមសាងសង់ទំនប់ ៤ផ្សេងទៀត (សេសាន ៣ សេសាន អា៣ សេសាន ៤ និងផ្លេករុង) ដោយឡែក ទំនប់យ៉ាលីបានសាងសង់ក្នុងឆ្នាំ១៩៩៣។

នៅក្នុងខែមករា ឆ្នាំនេះ អគ្គីសនីវៀតណាម និងគណៈកម្មាធិការជាតិទន្លេមេគង្គវៀតណាម និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាបានសន្យារៀបចំសិក្ខាសាលាសាធារណៈស្តីអំពីការវាយតម្លៃផលប៉ះពាល់បរិស្ថានទន្លេសេសាន។ សម្ព័ន្ធទន្លេកម្ពុជាបានស្វាគមន៍គំនិតផ្តួចផ្តើមនេះ និងអំពាវនាវដល់ភាគីពាក់ព័ន្ធត្រូវតែធានានូវដំណើរការត្រឹមត្រូវ ដូចនេះសហគមន៍ដែលរងគ្រោះដោយសារសាងសង់ទំនប់អាចចូលរួមយ៉ាងពេញលេញ។

ជាពិសេស សម្ព័ន្ធទន្លេកម្ពុជា សូមសំណូមពរដូចតទៅនេះ :

- ចែកជូននូវរបាយការណ៍នៃការវាយតម្លៃផលប៉ះពាល់បរិស្ថានទាំងភាសាខ្មែរនិងអង់គ្លេស យ៉ាងហោចណាស់មុនកិច្ចប្រជុំរយៈពេលមួយខែ ។
- ការបកប្រែជាភាសាខ្មែរនៃរបាយការណ៍សង្ខេប ត្រូវបានរៀបចំឡើងរយៈពេលយ៉ាងហោចណាស់មួយខែ មុនកិច្ចប្រជុំក្នុងករណីរឯកសារទាំងមូលមិនទាន់បកប្រែរួចរាល់ ។
- ការបកប្រែភាសាជាតិ និងអន្តរជាតិឱ្យបានសមរម្យសម្រាប់អ្នកចូលរួមត្រូវផ្តល់ឱ្យក្នុងអំឡុងពេលប្រជុំ ។
- ការចូលរួមមិនត្រូវគៀបសង្កត់ និងឆ្លុះបញ្ចាំងអំពីផលប្រយោជន៍អ្វីទាំងអស់ ។
- ផ្តល់ពេលគ្រប់គ្រាន់សម្រាប់ភាគីពាក់ព័ន្ធដើម្បីស្តាប់ស្ទង់មើលរបាយការណ៍ និងចែករំលែកពត៌មាន ព្រមទាំងផ្តល់មតិយោបល់ក្នុងពេលប្រជុំ ។
- ធានាដល់សហគមន៍ដែលរងគ្រោះអាចចូលរួមយ៉ាងពេញលេញក្នុងការប្រើភាសា និងការពិភាក្សាដែលពួកគាត់អាចយល់ និងឆ្លើយតបវិញបាន ។

សម្ព័ន្ធទន្លេកម្ពុជាមានការស្តោកស្តាយចំពោះកិច្ចប្រជុំកាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៧ ដែលមិនបានគោរពសិទ្ធិប្រជាពលរដ្ឋកម្ពុជាក្នុងដំណើរការពិគ្រោះយោបល់ប្រកបដោយភាពត្រឹមត្រូវ និងពេញលេញអំពីបញ្ហា ដែលរងប៉ះពាល់ ដល់អាយុជីវិតមនុស្សរាប់រយពាន់នាក់នៅតាមដងទន្លេសេសាន ។

ទោះបីយ៉ាងណាក៏ដោយ យើងសូមអះអាងនូវគោលជំហររួមរបស់យើងក្នុងការបន្តការពិភាក្សា និងសហការណ៍ជាមួយនឹងភាគីទាំងអស់ដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមាននៃការសាងសង់ទំនប់នៅតាមដងទន្លេ សេសាន យោងតាមច្បាប់ និងកិច្ចព្រមព្រៀងជាតិ និងអន្តរជាតិ ។

យើងនៅតែប្តេជ្ញាជំរុញឱ្យមានការអភិវឌ្ឍន៍និរន្តរភាព និងគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ប្រជាជន ទាំងអស់ ។

**ព័តិមានបន្ថែមសូមទំនាក់ទំនងជាមួយ :**


លោក **ឈិត សំអាត** - នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

ទូរស័ព្ទ (៨៥៥) ២៣ ២១៤៤២៩ អ៊ីមែល: samath@ngoforum.org.kh

លោក **គីម សង្ហា** - នាយកប្រតិបត្តិអង្គការបណ្តាញទន្លេសេសាន សេកុង និងស្រែពក

ទូរស័ព្ទ (៨៥៥) ១២ ៦២៩២២១ អ៊ីមែល: sesan@camintel.com

លោក **ទេព ប៊ុនណារិទ្ធិ** - នាយកប្រតិបត្តិសមាគមថែរក្សាបរិស្ថាន និងវប្បធម៌

ទូរស័ព្ទ (៨៥៥) ១២ ៨៩៥៦២៤ អ៊ីមែល: tep@cepa-cambodia.org

# វិវាទដីធ្លី និងដីព្រៃនៅស្រុក គាស់ក្រឡ រវាងអ្នកស្រុក និងក្រុមហ៊ុន

**ខេត្តបាត់ដំបង:** កាលពីរសៀលថ្ងៃទី២៧ ខែមិថុនា មានប្រជាពលរដ្ឋចំនួន ៥៨គ្រួសារ នៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ បានជួបជុំគ្នាធ្វើការតស៊ូមតិសុំឱ្យក្រុមអង្គការសង្គមស៊ីវិល និងសារព័ត៌មាន ជួយធ្វើការផ្សព្វផ្សាយ និងធ្វើអន្តរាគមន៍ទៅអាជ្ញាធរស្រុក ខេត្ត និងប្រមុខរាជរដ្ឋាភិបាល សុំជួយរកយុត្តិធម៌ឱ្យពួកគាត់ដែលទទួលរងការរំលោភយកដីធ្លីពីសំណាក់ក្រុមហ៊ុន និងអ្នកមានអំណាច។

លោកតា **ភឹម ហេង** អាយុ ៧២ឆ្នាំ ដែលអះអាងថាជាប្រជាពលរដ្ឋរងគ្រោះនៅភូមិ ឃុំ ខាងលើបានប្រាប់ឱ្យដឹងថា ប្រជាពលរដ្ឋភូមិកុយវែងទាំងអស់បាននាំគ្នាមកចាប់ដីសង់លំនៅឋាន និងធ្វើស្រែចំការចាប់តាំងពីឆ្នាំ១៩៩៨ មកក្រោយពីធ្វើសមាហរណកម្មកងទ័ពខ្មែរក្រហមចូលមករដ្ឋាភិបាល។ កាលនោះកំលាំងប្រដាប់អាវុធ អាជ្ញាធរស្រុក ខេត្ត បានប្រកាសឱ្យប្រជាពលរដ្ឋក្រីក្រគ្មានដីបង្កបង្កើនផល និងដីសង់លំនៅឋានទៅចាប់ដីនៅក្នុងស្រុកគាល់ក្រឡនេះដោយអាជ្ញាធរចែកដីឡូត៍ឱ្យមួយគ្រួសារទំហំ២០ម៉ែត្រ x ៥០ម៉ែត្រ ដីស្រែ ៥ហិកតា ដីចំការ ២ហិកតា។ ប្រជាពលរដ្ឋ និងគ្រួសារអតីតយោធាខ្មែរក្រហម និងគ្រួសាររដ្ឋាភិបាលបានច្របាច់បញ្ចូលគ្នា ហើយបានចាប់ដីរៀងៗខ្លួន និងសង់លំនៅឋានរស់នៅយ៉ាងប្រថុយប្រថានជាមួយនឹងចំការមីន និងគ្រាប់មិនទាន់ផ្ទុះ ព្រមទាំងរងនូវជំងឺគ្រុនចាញ់ និងខ្វះខាតឬអត់ទទួលទានទៀតផង។

លោកតាបានបន្តទៀតថា បន្ទាប់ពីការយកជីវិតទៅប្តូរនឹងគ្រាប់មីន គ្រាប់មិនទាន់ផ្ទុះ និងជំងឺគ្រុនចាញ់ ដើម្បីរុករានដីព្រៃមកសង់លំនៅឋាន និងធ្វើស្រែផ្គត់ផ្គង់ជីវភាពយ៉ាងត្រដាប់ត្រដួសអស់រយៈពេល ២ឆ្នាំ ទើបលោកឧបនាយករដ្ឋមន្ត្រី**ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញទៅប្រកាសទទួលស្គាល់បង្កើតភូមិដោយដាក់ឈ្មោះថា ភូមិកុយវែង។ ចំណែកលោកអភិបាលខេត្តបានឈូសឆាយផ្លូវ ហើយកម្មវិធីសិលាបានប្រមូលថវិកាបដិភាគពីប្រជាពលរដ្ឋ កសាងបានផ្លូវលំមួយខ្សែក្រាលក្រួសក្រហមពីទីរួមស្រុកគាស់ក្រឡមកកាន់ភូមិកុយវែងនេះ ដែលធ្វើអោយប្រជាពលរដ្ឋមានផ្លូវថ្នល់ធ្វើដំណើរទៅទីផ្សារ នាំកូនចៅទៅសាលារៀន និងទៅមណ្ឌលសុខភាព។ ផ្ទុយទៅវិញ ខណៈពេលដែលកំពុងតែរីករាយនឹងជីវិតថ្មីដែលប្រមុខរាជរដ្ឋាភិបាល និងអាជ្ញាធរបានផ្តល់ឱ្យ ក៏ស្រាប់តែមានទំនាស់ដីធ្លីកើតឡើងនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៧ ដោយលោក **លឹម នាឡេង** បាននាំកម្លាំងប្រដាប់អាវុធ ត្រាក់ទ័រ អេស្កាវ៉ាទ័រ អាប៊ុល មកធ្វើសកម្មភាពឈូសឆាយ ភ្ជួរ រំលោភយកដីស្រែរបស់ប្រជាពលរដ្ឋដែលនៅតំបន់នោះ។

ដោយសារមានសកម្មភាពបែបនេះ ប្រជាពលរដ្ឋក៏បានប្តឹងទៅអាជ្ញាធរភូមិ ឃុំ ស្រុក ខេត្ត ដើម្បីរកយុត្តិធម៌ឱ្យពួកគាត់ ហើយអាជ្ញាធរស្រុកក៏បានឱ្យភាគីលោក **លឹម នាឡេង** ផ្អាកសកម្មភាព តែក្រុមហ៊ុននេះមិនបានផ្អាកទេ គឺនៅតែធ្វើការឈូសឆាយ ភ្ជួរ និងរំលោភដីស្រែរបស់ពួកគាត់ទៀត។ លុះនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ មានមន្ត្រីអាជ្ញាធរ ស្រុក ខេត្ត និងអង្គការសិទ្ធិមនុស្សចូលធ្វើការដោះស្រាយ ហើយជាលទ្ធផលគឺ ភាគីលោក **លឹម នាឡេង** បានយល់ព្រមប្រគល់ដីឱ្យភាគីប្រជាពលរដ្ឋ ៥៨គ្រួសារ ក្នុងមួយគ្រួសារ ២ហិកតា និងដោយសារមានការគាបសង្កត់ផង ភាគីប្រជាពលរដ្ឋក៏យល់ព្រម និងផ្តិតមេដៃទទួលយកដីស្រែទំហំ ២ហិកតាក្នុងមួយគ្រួសារ។

លោកតា **ភឹម ហេង** បានរៀបរាប់បន្តទៀតថា លុះពេលមកទទួលដីស្រែស្រាប់តែលោក **លឹម នាឡេង** ប្រគល់ដីឱ្យចំនួន ២ហិកតា គិតទាំងដីភូមិសង់លំនៅ និងដីស្រែ ហើយបានដេញប្រជាពលរដ្ឋអោយរុះរើផ្ទះចេញពីកន្លែងរស់នៅឱ្យទៅនៅដីដែលក្រុមហ៊ុនប្រគល់ឱ្យនៅចំងាយពីផ្ទះចាស់ ៣គីឡូម៉ែត្រ គឺទៅដល់ក្នុងព្រៃ គ្មានមណ្ឌលសុខភាព គ្មានទឹកស្អាតប្រើប្រាស់។ ដោយសារមូលហេតុនេះហើយ ទើបប្រជាពលរដ្ឋធ្វើការប្តឹងតវ៉ាតាមរយៈអង្គការសង្គមស៊ីវិល និងសូមឱ្យសារព័ត៌មានជួយធ្វើការផ្សព្វផ្សាយ និងធ្វើអន្តរាគមន៍ទៅអាជ្ញាធរស្រុក ខេត្ត និងប្រមុខរាជរដ្ឋាភិបាល សូមមេត្តាជួយដោះស្រាយឱ្យប្រជាពលរដ្ឋទាំង ៥៨គ្រួសារ នៅភូមិកុយវែង អោយបានរស់ និងគ្រប់គ្រងដីធ្លីជាកម្មសិទ្ធិស្របច្បាប់ គឺប្រជាពលរដ្ឋព្រមយកស្រែចំនួន ២ហិកតា និងដីឡូត៍សង់ផ្ទះរស់នៅសព្វថ្ងៃតាមក្បាលដីអមផ្លូវលំដដែល ដោយមិនព្រមទទួលដីថ្មីដែលក្រុមហ៊ុនប្រគល់ឱ្យនោះទេ។ ចំពោះសំណូមពរដំណោះស្រាយនេះ គឺសូមអោយបានឆាប់រហ័សបំផុតអោយប្រជាពលរដ្ឋបានធ្វើស្រែទាន់រដូវ ព្រោះបើឆ្នាំនេះមិនបានធ្វើស្រែទេ ប្រជាពលរដ្ឋពិតជាដាច់ពោះស្លាប់ជាមិនខាន។

ចំនែកតំណាងក្រុមហ៊ុនលោក **លឹម នាឡេង** បានឱ្យដឹងថា ក្រុមហ៊ុនបានទិញដីចំនួន ៦៦០ហិកតា ពីមន្ត្រីយោធាកាលពីឆ្នាំ១៩៩៨ ដើម្បីដាំដំឡូងមី និងដីទំនប់ធ្វើស្រែ ដាំស្រូវ លុះដល់ឆ្នាំ២០០០ ស្រាប់តែប្រជាពលរដ្ឋចូលគាស់យកដីក្រុមហ៊ុនមកធ្វើជាកម្មសិទ្ធិ។ កាលនោះ ក្រុមហ៊ុនបានប្តឹងចូលតុលាការ និងអាជ្ញាធរខេត្ត ប៉ុន្តែពុំមានដំណោះស្រាយ ហើយនៅខែមិថុនា ឆ្នាំ២០០៧ ដោយក្រុមហ៊ុនត្រូវការអភិវឌ្ឍន៍ ទើបធ្វើការឈូសឆាយ ហើយប្រជាពលរដ្ឋយល់ព្រមទទួលយកដំណោះស្រាយនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៧ ក្រុមហ៊ុនយល់ព្រមប្រគល់ដីចំនួន ២ហិកតា ក្នុងមួយគ្រួសារ។ ក្នុងដំណោះស្រាយនោះ ក្រុមហ៊ុនធានាឈូសឆាយ ភ្ជួរ ដីឱ្យ លើកភ្លឺស្រែឱ្យ មានទំហំ ២ហិកតាម្នាក់ និងជីកប្រឡាយលើកផ្លូវលំព័ទ្ធជុំវិញផ្ទៃដីទាំង ៥៨គ្រួសារ ដែលមានទទឹងក្បាលដី ៦០០ម៉ែត្រ បណ្តោយ ២០០០ម៉ែត្រ ហើយឱ្យប្រជាពលរដ្ឋរុះរើផ្ទះសង់លើដីដែលក្រុមហ៊ុនបានរៀបចំទុកឱ្យនៅខាងក្រោយដីទំនាស់ ៣គីឡូម៉ែត្រ ព្រមទាំងបានលើកផ្លូវលំតភ្ជាប់មកផ្លូវលំចាស់នេះទៀត គ្រាន់តែពុំទាន់បានចាក់ក្រួសក្រហមប៉ុណ្ណោះ។

លោកអភិបាលស្រុកបានមានប្រសាសន៍ថា ស្រុកគាស់ក្រឡ គឺជាតំបន់ប្រទាញប្រទង់នៅពេលសង្គ្រាម លុះនៅឆ្នាំ១៩៩៨ ក្រោយពីសង្គ្រាមត្រូវបានបញ្ចប់ ក៏បានធ្វើសមាហរណកម្មកងទ័ពខ្មែរក្រហម និងកងទ័ពរាជរដ្ឋាភិបាល ហើយរាជរដ្ឋាភិបាលបានប្រកាសថា កងទ័ព និងគ្រួសារកងទ័ពឈរជើងនៅកន្លែងណា សូមឱ្យរក្សាការឈរជើងនៅកន្លែងនោះ។ ដូច្នោះគ្រួសារយោធិននានាក៏បានហៅបងប្អូនសាច់ញាតិមករស់នៅ ហើយស្រុកគាស់ក្រឡនោះគឺជាតំបន់តំរប់ព្រៃឈើ និងមានប្រជាជនរស់នៅតាំងពីសម័យសង្គមរាស្ត្រនិយម។ ស្រុកគាស់ក្រឡនេះត្រូវបានបង្កើតឡើងនៅក្នុងសម័យ **លន់ ណុល** កាលពីសម័យ **ប៉ុល ពត** ក៏មានមនុស្សរស់នៅដែររហូតមកដល់ពេលធ្វើសមាហរណកម្មរួចយោធភូមិភាគ ៥ ក៏បានបង្កើតតំបន់នេះ ជាតំបន់អភិវឌ្ឍន៍សម្រាប់យោធិនរំសាយ ក៏ប៉ុន្តែពុំបានអភិវឌ្ឍន៍អ្វីទេ។

លោកអភិបាលស្រុកបានបន្តទៀតថា ប្រជាពលរដ្ឋដែលខ្វះខាតដីសង់លំនៅឋាន និងដីក្របករបរកសិកម្ម ក៏បាននាំគ្នាមកចាប់ដីសង់លំនៅឋាន និងដីធ្វើស្រែចំការ តាមរយៈបងប្អូនគ្រួសារយោធិនរហូតមាន ៥១ភូមិ និងមានប្រជាជនចំនួន ៥.៣៣៤ គ្រួសារ ។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០០ លោកឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានប្រកាសបង្កើតស្រុកគាស់ក្រឡឡើងវិញ ដូច្នេះបញ្ហាគ្រប់គ្រង់រដ្ឋបាលមានការលំបាកដោយសារគ្រួសារយោធិនបានលក់ដូរដីធ្លីដោយខ្លួនឯង ។ ឯប្រជាពលរដ្ឋមកពីក្រៅចូលចាប់ដីសង់លំនៅឋាន និងកាប់រានដីធ្វើស្រែពាសពេញតំបន់ ទើបពេលប្រកាសតំបន់បង្កើតស្រុក ស្រាប់តែមានទំនាស់ដីធ្លីកើតឡើង ដោយខ្លះលក់ដី ហើយទៅរស់នៅកន្លែងថ្មី ឯមន្ត្រីយោធានៃមណ្ឌលអភិវឌ្ឍន៍របស់ខ្លួនទៅអោយក្រុមហ៊ុនលោក **លឹម ឆាឡេង** ដែលមានប្រជាពលរដ្ឋរស់នៅជាង ១០០គ្រួសារ ។ នៅស្រុកគាស់ក្រឡនេះ តំបន់រដ្ឋបាលព្រៃឈើគ្រប់គ្រងមានផ្ទៃដីសរុប ១៦១.៥៤ហិកតា ព្រៃពាក់កណ្តាលស្រោង ៤១.៩៤២ហិកតា ព្រៃរបោះ ៦៣.២៨៦ហិកតា ព្រៃផ្សេងៗ ២.៦០២ហិកតា និងព្រៃសម្បទាន ២៨.៥៨០ហិកតា ។ រីឯដីសម្រាប់លំនៅឋាន និងដីស្រែសរុប ១៥.០០០ហិកតា ក៏ប៉ុន្តែការអនុវត្តន៍ធ្វើស្រែចំការជាក់ស្តែងបានតែ ៥.០០០ហិកតាទេ ដូច្នោះប្រជាពលរដ្ឋត្រូវខ្វះខាត់ដីធ្វើស្រែចំការជីវភាពក្រីក្រលំបាក ។

លោកអភិបាលស្រុកបានថ្លែងទៀតថា ដោយសារតែភាពក្រីក្រនេះហើយ ទើបប្រជាពលរដ្ឋនាំគ្នាកាប់ព្រៃឈើរុករានដីបន្ត ដើម្បីយកដីធ្វើកសិកម្មចិញ្ចឹមជីវិត ហើយទំនាស់ដីធ្វើកើតឡើងពិបាកក្នុងការដោះស្រាយ ជាពិសេសទំនាស់ដីធ្លីជាមួយក្រុមហ៊ុនដោយមន្ត្រីយោធាជាអ្នកលក់ធ្វើឱ្យប៉ះពាល់ដល់ដីប្រជាពលរដ្ឋ ទោះជាយ៉ាងណា អាជ្ញាធរកំពុងព្យាយាមដោះស្រាយជម្លោះដីធ្លីដ៏ស្មុគស្មាញនេះ ។

*អត្ថបទដោយលោក **ហ៊ុច សារ៉ាន់** ទីប្រឹក្សាគំរោងព្រៃឈើ និងចំការឈើដាំវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។*



គ្រឿងចក្រសំរាប់ឈូសឆាយដីព្រៃ



ការជួបប្រជាពលរដ្ឋទទួលរងផលប៉ះពាល់ពីការឈូសឆាយដីព្រៃ

# ការយល់ដឹង និងការពារបរិស្ថាននៅតែជាបញ្ហាចំបងសំរាប់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្ន

ស្របពេលដែលបច្ចេកវិទ្យាកាន់តែទំនើបការទាញយកធនធានធម្មជាតិក៏កាន់តែមានបរិមាណច្រើនដើម្បីបំពេញតំរូវការអភិវឌ្ឍន៍។ បើកាលណាតំរូវការរបស់មនុស្សកាន់តែច្រើន ជាការពិតវានឹងនាំអោយធនធានធម្មជាតិកាន់តែថយចុះ ដោយសារតែពុំមានតុល្យភាពនៅក្នុងការប្រើប្រាស់ និងអភិរក្សនូវធនធានធម្មជាតិទាំងនោះ។

ជាក់ស្តែងនាពេលបច្ចុប្បន្ននេះ ការអភិវឌ្ឍន៍បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើធនធានធម្មជាតិ ហើយថែមទាំងបានផ្តល់មកវិញនូវផលអវិជ្ជមានទៅលើសង្គម និងប្រជាជន។ តួយ៉ាងដូចជាគំរោងអភិវឌ្ឍន៍នានានៅក្នុង និងជុំវិញបឹងទន្លេសាបបាននឹងកំពុងបំផ្លាញទៅលើព្រៃលិចទឹក ធនធានមច្ឆាជាតិ បក្សាបក្សី ប្រព័ន្ធអេកូឡូស៊ីជាដើម ដែលមិនអាចស្តារឡើងវិញអោយដូចដើមបានឡើយ។ ការនេសាទខុសច្បាប់ ការកាប់បំផ្លាញព្រៃលិចទឹកសំរាប់កសិកម្ម ការប្រើថ្នាំគីមីកសិកម្ម និងការអនុវត្តន៍ច្បាប់បទដ្ឋានគ្រប់គ្រងនៅមានកំរិតនៅឡើយ សុទ្ធតែរួមចំណែកទៅលើការវិនាសហិនហោចធនធានធម្មជាតិរបស់យើង។ យ៉ាងច្បាស់ផងដែរនោះ គំរោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីដើម្បីការអភិវឌ្ឍន៍ប្រទេស បានធ្វើអោយប្រជាពលរដ្ឋទន់ខ្សោយបាត់បង់នូវទ្រព្យសម្បត្តិ ប្រពៃណីវប្បធម៌ ដីស្រែចំការ និងអាយុជីវិតផងដែរ។ ដូចនេះ យើងត្រូវចេះថ្លឹងថ្លែងអំពីការអភិវឌ្ឍន៍ និងការអភិរក្សដើម្បីអោយសំរេចបាននូវនិរន្តភាពនៃការអភិវឌ្ឍន៍នេះ ។

មួយរយៈកាលកន្លងមកនេះយើងសង្កេតឃើញថាការយល់ដឹង និងកិច្ចការការពារបរិស្ថានរបស់ប្រជាជនកម្ពុជានៅមានកំរិតនៅឡើយ។ ប៉ុន្តែទន្ទឹមនឹងនេះដែរ យើងក៏សង្កេតឃើញមានការប្រែប្រួលផងដែររបស់ឥរិយាបទប្រជាជនក្នុងការយល់ដឹងអំពីបញ្ហាបរិស្ថាននេះក្នុងសន្ទុះមួយយឺតៗ និងសន្សឹមៗ។ បញ្ហាបរិស្ថាននៅតែបន្តមានវត្តមាននៅគ្រប់ខេត្តក្រុងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ហើយពីមួយថ្ងៃទៅមួយថ្ងៃបញ្ហាបរិស្ថាននេះកាន់តែមានលក្ខណៈប្លែកៗ និងធ្ងន់ធ្ងរគួរអោយព្រួយបារម្ភ។ ការបាត់បង់គំរបព្រៃឈើ ការប្រើប្រាស់ថ្នាំគីមីកសិកម្មដែលមានផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គមមនុស្ស ការកើនឡើងនូវការបំពុលបរិយាកាសតាមរយៈផ្សែងបំពុលពីទោចក្រយានយន្ត រោងចក្រ និងឧស្សាហកម្ម ការបរបាញ់ និងធ្វើអាជីវកម្មសត្វព្រៃដោយខុសច្បាប់ ការបោះបង់ចោលកាកសំណល់ឬសំរាមពាសវាលពាសកាល ការបង្ហូរទឹកស្អុយបំពុលទៅក្នុងបឹងឬទន្លេធម្មជាតិ ការនេសាទខុសច្បាប់ និងបញ្ហា បរិស្ថានជាច្រើនផ្សេងៗទៀតដែលកំពុងតែមានសភាពធំ និងច្បាស់ឡើងៗ។ ទាំងអស់នេះជាលទ្ធផលពីសកម្មភាពរបស់មនុស្សដែលខ្វះការយល់ដឹង និងការពិចារណាអោយបានល្អិតល្អន់ និងគ្រប់ជ្រុងជ្រោយក្នុងការប្រើប្រាស់ធនធានធម្មជាតិ។ ការការពារដែលប្រកបដោយវិចារណញ្ញាណ និងនិរន្តភាពទាមទារអោយមានការចូលរួមពីគ្រប់បណ្តាភាគីពាក់ព័ន្ធ ជាពិសេសគឺតួនាទីរបស់បុរស និងស្ត្រីនៅក្នុងបរិបទនេះ។

នាពេលបច្ចុប្បន្ននេះ មានស្ថាប័ន និងអង្គការនានាបាននឹងកំពុងធ្វើការយ៉ាងសកម្មលើការងារលើកកំពស់ ស្ត្រីនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងកិច្ចការពារបរិស្ថាននេះ។ ប៉ុន្តែស្ថាប័ន និងអង្គការទាំងនោះបានជួបប្រទះបញ្ហាជាច្រើនដែលពាក់ព័ន្ធ និងចំណេះដឹងអំពីយេនឌ័រមានការរើសអើងចំពោះស្ត្រីនៅតាមតំបន់មួយចំនួន ការលើកកំពស់ស្ត្រីនៅពុំទាន់ទូលំទូលាយ ការចូលរួម និងចំណេះដឹងរបស់ស្ត្រីនៅមានកំរិតនៅឡើយ និងការផ្តល់អោយឱកាស និងអំណាចអោយស្ត្រីនៅមិនទាន់ពេញលេញនៅឡើយផងដែរ។ បញ្ហាទាំងនេះអាចដោះស្រាយទៅបានដរាបណាស្ថាប័ន ឬអង្គការពាក់ព័ន្ធដែលជាដៃគូដែលធ្វើការងារនេះមានសមត្ថភាព បទពិសោធន៍ច្រើនសំរាប់ជួយសំរួលដល់ការបញ្ជ្រាប និងលើកកំពស់យេនឌ័រនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ។ ដំណោះស្រាយនេះមានតែការចូលរួមផ្តល់បទពិសោធន៍ និងចំណេះដឹងរវាងគ្នាទៅវិញទៅមកអំពីឧទាហរណ៍ជាក់ស្តែងក្នុងការធ្វើការងារជាមួយស្ត្រី។ ដើម្បីគ្រប់គ្រងអោយបាននូវធនធានធម្មជាតិ និងបរិស្ថាន តួនាទីរបស់ស្ត្រីគឺមានសារៈសំខាន់ណាស់។



សកម្មភាពសិស្ស-និស្សិត មន្ត្រីរាជការ និងអង្គការនានាចូលរួមក្នុងទិវា [illegible]

មួយរយៈកាលដើមឆ្នាំ២០០៧ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ជាពិសេសជាមួយនិងគំរោងលើកកំពស់ចំណេះដឹង និងកិច្ចការពារបរិស្ថាន បានខិតខំយកអស់កំលាំងកាយ និងចិត្តក្នុងការលើកកំពស់ចំណេះដឹង និងបទពិសោធន៍ល្អៗជាច្រើនក្នុងការការពារ និងគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សកម្មភាព និងទិសដៅជាច្រើនត្រូវបានលើកឡើង និងអនុវត្តយ៉ាងល្អប្រសើរ និងជោគជ័យតាមរយៈការបណ្តុះបណ្តាលសមត្ថភាពដល់សមាជិកបណ្តាញបរិស្ថាន ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការបញ្ជ្រាបយេនឌ័រនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថាន ការរៀបចំអោយមានទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ អំពីបញ្ហានិងដំណោះស្រាយបរិស្ថានសំរាប់សមាជិកបណ្តាញបរិស្ថាន និងផែនការសកម្មភាពជាអត្ថិភាពមួយចំនួនធំផងដែរ។ សកម្មភាព និងលទ្ធផលទាំងនេះបានរួមចំណែកយ៉ាងច្រើននៅក្នុងការលើកកំពស់ចំណេះដឹងរបស់ប្រជាជនកម្ពុជាក្នុងការរួមរួបគ្នាការពារ និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តភាព។ លទ្ធផលទាំងនេះមិនអាចសំរេចបានក្នុងរយៈខ្លីឬឆាប់ៗនោះទេ តែទាមទារពេលវេលាយូរអង្វែង និងធនធានជាច្រើនក្នុងការផ្លាស់ប្តូរឥរិយាបទ អាកប្បកិរិយា និងការគិតរបស់មនុស្សអោយងាកមកគិតគូថែរក្សា និង ការពារធនធានធម្មជាតិទាំងនេះ ដើម្បីរួមចំណែកក្នុងការដោះស្រាយបញ្ហាទាំងនេះ បណ្តាអ្នកពាក់ព័ន្ធទាំងឡាយទាំងរដ្ឋាភិបាល អង្គការ ស្ថាប័ន និងប្រជាពលរដ្ឋ ត្រូវតែយល់ដឹងនូវបញ្ហាជាក់ស្តែង និងច្បាប់នានាទាំងនោះ ហើយរួបរួម សហការគ្នាល្អក្នុងស្មារតីអភិរក្ស និងថែរក្សាធនធានធម្មជាតិ។ អាជ្ញាធរត្រូវចូលរួម និងសហការអោយបានល្អប្រសើរជាមួយនិងអង្គការសង្គមស៊ីវិលនានា ដើម្បីបណ្តុះបណ្តាលផ្សព្វផ្សាយនូវចំណេះដឹង និងបទពិសោធន៍ក្នុងការថែរក្សា និងការពារបរិស្ថាន។ ប្រជាជនខ្លួនឯងផ្ទាល់ត្រូវមានស្មារតីភ្ញាក់រលឹកខ្ពស់ ចូលរួមសកម្មភាពនានាក្នុងការស្តារ និងថែរក្សាសម្បត្តិធម្មជាតិទាំងនេះ។ គោលនយោបាយជាតិត្រូវតែបំរើវិភាគស្ត្រជាធំដោយរួមបញ្ចូលទាំងការអភិវឌ្ឍន៍ និងការអភិរក្សជាមួយគ្នាដើម្បីសំរេចអោយបាននូវចិរភាពបរិស្ថាន និងការអភិវឌ្ឍន៍សំរាប់ពេលបច្ចុប្បន្ននិងអនាគត។

*អត្ថបទដោយលោក **សំ ចាន់ធី** មន្ត្រីគំរោងបរិស្ថាននៃ*
*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

## ហេតុអ្វីបានជាចាំបាច់ត្រូវមានតួនាទីស្ត្រីក្នុងការការពារ និងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន?

យេនឌ័រមានតួនាទីយ៉ាងសំខាន់នៅក្នុងប្រទេសកម្ពុជាដោយបានអំណោយផលអោយស្ត្រីមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនិងធនធានធម្មជាតិដូចជាព្រៃឈើ ទឹកដី និងសត្វព្រៃជាដើមនៅក្នុងប្រទេសកម្ពុជា។ ស្ត្រីទាំងនោះបានប្រើប្រាស់ និងអភិរក្សនូវធនធានធម្មជាតិទាំងឡាយដើម្បីផ្គត់ផ្គង់នូវតំរូវការចាំបាច់នានាសំរាប់គ្រួសារ សហគមន៍ និងជាតិ ។ ដូចនេះ ការអភិរក្សធនធានធម្មជាតិនៅតាមតំបន់ជនបទនានាមិនអាចធ្វើទៅបានជោគជ័យទេដរាបណាមិនការចូលរួមរបស់ស្ត្រី។ ស្ត្រីច្រើនតែពឹងផ្អែកលើធនធានដែលមាននៅជុំវិញភូមិ និងព្រៃជិតៗនោះសំរាប់ចិញ្ចឹមគ្រួសាររបស់ខ្លួន។ បុរស និងស្ត្រីសុទ្ធតែបានរួមវិភាគទានយ៉ាងសំខាន់ដល់គ្រួសារ និងសហគមន៍ទាំងមូលគ្រាន់តែវិភាគទាន



សកម្មភាពរបស់ស្ត្រីក្នុងការបញ្ចេញមតិយោបល់ និងពិភាក្សាក្នុងសិក្ខាសាលា ស្តីអំពីការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថាន

នោះវាមានលក្ខណៈខុសៗគ្នាតែប៉ុណ្ណោះ ។ ដើម្បីអោយការងារគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថានមានប្រសិទ្ធិភាព យើងត្រូវទទួលស្គាល់នូវភាពខុសគ្នាទាំងឡាយនេះ ជាពិសេសមិនត្រូវមើលរំលងការចូលរួមរបស់ស្ត្រីឡើយ ។

វាជាចំណេះដឹងមូលដ្ឋានមួយនៅតាមតំបន់ជនបទនៃប្រទេសកម្ពុជាដែលថាស្ត្រីពិតជាអ្នកចូលរួមចំណែកក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ ស្ត្រីជនបទភាគច្រើនជាអ្នកក្រីក្រ និងពុំទទួលបានការអប់រំឡើយ ព្រមទាំងធ្វើការងារខ្លះពុំបានទទួលប្រាក់កំរៃ ។ ដូចនេះស្ត្រីនៅតាមជនបទភាគច្រើនគ្មានឥទ្ធិពល និងសកម្មភាពគួរអោយស្ញប់ស្ញែងក្នុងការគ្រប់គ្រងធនធានធម្មជាតិនោះទេ ។ ស្ត្រីច្រើនតែជាអ្នកទទួលបន្ទុកក្នុងការដងទឹកសំរាប់ប្រើប្រាស់ រកអុស រកត្រី ដើររកម្ហូប និងថ្នាំសង្កូវនៅតាមព្រៃថែមទៀតផង ។ ស្ត្រីច្រើនតែប្រើប្រាស់ធនធានពីតំបន់ផ្សេងៗច្រើនជាងបុរស ជារឿយៗតំបន់ព្រៃឈើណាដែលនៅជិតៗភូមិ ។ ជាការចាំបាច់ណាស់ដែលស្ត្រីត្រូវចូលរួមផ្តល់នូវចំណេះដឹងដើម្បីជាវិភាគទានដល់ការរៀបចំធ្វើផែនការក្នុងការប្រើប្រាស់ធនធានធម្មជាតិ និងការការពារបរិស្ថាន ។ អ្នកពាក់ព័ន្ធទាំងឡាយគួរតែសង្កេតមើលអោយបានដិតដល់ និងជំរុញអោយមានការចូលរួមរបស់ស្ត្រី និងបុរសជាមួយគ្នា ។ ជួនកាលស្ត្រីមានការអៀនខ្មាស់ក្នុងការបញ្ចេញយោបល់នៅពេលមានសមាសភាពផ្សេងៗខុសៗពីគ្នាឬនៅពេលដែលមានបរិមាណស្ត្រីតិចតួច ។

នាពេលបច្ចុប្បន្ននេះ មានស្ថាប័ន និងអង្គការនានាបាននឹងកំពុងធ្វើការយ៉ាងសកម្មលើការងារលើកកំពស់ស្ត្រីនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងកិច្ចការពារបរិស្ថាននេះ ។ ប៉ុន្តែស្ថាប័ន និងអង្គការទាំងនោះមានជួបប្រទះបញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងចំណេះដឹងអំពីយេនឌ័រ និងការរើសអើងចំពោះស្ត្រីនៅតាមតំបន់មួយចំនួន ។ ការលើកកំពស់ស្ត្រីនៅពុំទាន់ទូលំទូលាយ ការចូលរួម និងចំណេះដឹងរបស់ស្ត្រីនៅមានកំរិតនៅឡើយ និងការផ្តល់ឱកាស និងអំណាចអោយស្ត្រីនៅមិនទាន់ពេញលេញនៅឡើយផងដែរ ។ បញ្ហាទាំងនេះ អាចដោះស្រាយទៅបានដរាបណាស្ថាប័នឬអង្គការពាក់ព័ន្ធដែលជាដៃគូធ្វើការងារនេះមានសមត្ថភាព បទពិសោធន៍ច្រើនសំរាប់ជួយសំរួលដល់ការបញ្ជ្រាប និងលើកកំពស់យេនឌ័រនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ ដំណោះស្រាយនេះមានតែការចូលរួមផ្តល់បទពិសោធន៍ និងចំណេះដឹងរវាងគ្នាទៅវិញទៅមកក្នុងការធ្វើការងារជាមួយស្ត្រី ។ ដើម្បីគ្រប់គ្រងអោយបាននូវធនធានធម្មជាតិ និងបរិស្ថាន តួនាទីរបស់ស្ត្រីគឺមានសារៈសំខាន់ណាស់ ។

គំរោងសហគមន៍ឬគំរោងអភិរក្សឬអភិវឌ្ឍន៍ទាំងឡាយណាដែលមិនបានស្វែងយល់ និងដោះស្រាយបញ្ហាតួនាទីយេនឌ័រ ហាក់បីដូចជាកំពុងតែមើលរំលងមួយផ្នែកធំនៃចំណេះដឹង បទពិសោធន៍ការយល់ដឹង និងគំនិតដ៏ពិសិដ្ឋ ហើយការដែលទទួលយកតែទស្សនៈរបស់បុរសតែម្យ៉ាងនេះអាចនាំទៅដល់ការធ្វើសេចក្តីសំរេចចិត្តខុស ។ ការងារសហគមន៍ដែលគោរពតាមយេនឌ័រមិនមែនមានន័យថាត្រូវតែកែទំលាប់ការងាររបស់សហគមន៍នោះទេ ។ ប៉ុន្តែសកម្មភាពរបស់គំរោងត្រូវទទួលស្គាល់ពីតួនាទីយេនឌ័រ និងដោះស្រាយតំរូវរបស់សហគមន៍ទាំងមូល ។ និយាយជារួមតួនាទីរបស់ស្ត្រីមានសារៈសំខាន់ណាស់ក្នុងការងារគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការការពារបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ។

*អត្ថបទដោយ **សំ ចាន់ធី** មន្ត្រីគំរោងបរិស្ថាននៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

# កិច្ចប្រជុំរវាងរដ្ឋបាលព្រៃឈើ និង គណៈកម្មការសហគមន៍

កិច្ចប្រជុំមួយរវាងរដ្ឋបាលព្រៃឈើ និងគណៈកម្មការសហគមន៍ត្រូវបានរៀបចំឡើងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ នៅក្នុងខណ្ឌរដ្ឋបាលព្រៃឈើស្ថិតនៅក្នុងឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។ នៅក្នុងកិច្ចប្រជុំនោះមានសមាជិកដែលមកពីបណ្តាអង្គការ និងស្ថាប័នពាក់ព័ន្ធជាច្រើន រួមមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់ជាតិ និងខេត្ត គណៈកម្មការសហគមន៍តំណាងសហគមន៍ អភិបាលស្រុកសណ្តាន់ ក្រុមប្រឹក្សាឃុំ និងមេភូមិ ។ កិច្ចប្រជុំប្រព្រឹត្តទៅក្រោមការសំរបសំរួលពីវេទិការនៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។ ក្នុងកិច្ចប្រជុំនោះ មានចំនួនអ្នកចូលរួមសរុប ៤២នាក់ ដែលនៅក្នុងនោះមានស្រីចំនួន ១០នាក់ ។

លោក **ឃុន ប៊ុនណាត** ជាប្រធានកម្មវិធីផ្នែកដីធ្លី និងជីវភាពបានបញ្ជាក់ថា កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងដើម្បីធ្វើអោយ សហគមន៍ព្រៃឈើមានទំនាក់ទំនងកាន់តែល្អជាមួយនឹងរដ្ឋបាលព្រៃឈើ ហើយនឹងជួយរកយុទ្ធសាស្ត្រថ្មីៗសំរាប់សហគមន៍ក្នុងការការពារធនធានព្រៃឈើ ។ លោកក៏បានកោតសរសើរដែរថា សហគមន៍នេះស្ថិតនៅក្នុងទីតាំងល្អ ព្រោះជាតំបន់ដែលមានធនធានព្រៃឈើសំបូរបែប ។ លោកបានបន្ថែមទៀតថា សហគមន៍គួរតែកុំពឹងផ្អែកទៅលើអង្គការមិនមែនរដ្ឋាភិបាលពេក តែផ្ទុយទៅវិញ ត្រូវតែបង្កើននូវទំនាក់ទំនងអោយកាន់តែល្អជាមួយនឹងរដ្ឋបាលព្រៃឈើ និងអាជ្ញាធរដែនដីទើបល្អជាង ។ ម្យ៉ាងទៀតត្រូវធ្វើការពង្រឹងផ្ទៃក្នុង និងលើកទឹកចិត្តអោយមានការចូលរួមច្រើនឡើងពីសមាជិករបស់ខ្លួនតាមរយៈការផ្សព្វផ្សាយនានា ។ល ។

លោក **គង់ ណារិន** នាយខ័ណ្ឌរដ្ឋបាលព្រៃឈើ បានមានប្រសាសន៍ថា ប្រជាជនមានសិទ្ធិនៅក្នុងការកាប់ឈើដើម្បីយកមកធ្វើលំនៅដ្ឋាន កុំអោយតែយើងកាប់ឈើនោះយកទៅលក់ ហើយយើងត្រូវតែមានលិខិតលាយលក្ខអក្សរពីអាជ្ញាធរភូមិ ឃុំ ។ លោកបានបន្ថែមទៀតថា ដោយសារតែភាពក្រីក្រទើបប្រជាជនទាំងនោះឃ្លាតឆ្ងាញពីការយល់ដឹងអំពីសិទ្ធិរបស់ពួកគេក្នុងការប្រើប្រាស់ធនធានធម្មជាតិស្របច្បាប់ ។

លោក **ឡាច សេដ្ឋាផល** អនុប្រធានការិយាល័យសហគមន៍ព្រៃឈើនៃរដ្ឋបាលព្រៃឈើថ្នាក់ជាតិ បានមានប្រសាសន៍អំពីប្រវត្តិនៃពាក្យសហគមន៍នេះថា ពាក្យនេះកើតឡើងតាំងពីឆ្នាំ១៩៩២ មកដល់ឆ្នាំ២០០២ ហើយការបង្កើតសហគមន៍នេះមានការគាំទ្រពីរដ្ឋាភិបាល ។ លោកក៏បានរៀបរាប់ទៀតថា យើងគួរតែធ្វើការយល់អំពីដំណើរការរបស់សហគមន៍ជាមុនសិន ។ ដំណើរការដំបូងយើងចាំបាច់ត្រូវរៀបចំឯកសារដោយមានផ្តិតមេដៃគាំទ្ររបស់ប្រជាពលរដ្ឋជាមុនសិន ហើយនិងធ្វើការពិគ្រោះយោបល់ជាមួយនឹងរដ្ឋបាលព្រៃឈើជាមុនសិន មុននឹងបញ្ជូលឯកសារនេះដើម្បីដាក់ស្នើរជូនទៅអភិបាលខេត្តធ្វើការសំរេច ។

សហគមន៍ឃុំក្បាលដំរីក៏បានមានមតិយោបល់ ដោយស្នើសុំអោយមានជំនួយបន្ថែមទាក់ទងទៅនឹងការអភិរក្សព្រៃនៅក្នុងតំបន់អោយបានល្អ ។ ជាងនេះទៅទៀតខាងតំណាងសហគមន៍មានរិទ្ធនៅស្រុកសណ្តាន់បានលើកឡើងថា ប្រជាពលរដ្ឋនៅឃុំទីរីងបានធ្វើការកាប់ព្រៃនៅឃុំមានរិទ្ធ ដែលព្រៃនោះគឺជា

ព្រៃរបស់សហគមន៍ហើយលោក **ស៊ិន សៀន** បាននាំកំលាំងមកទប់ស្កាត់ និងធ្វើការណែនាំថា ការកាប់របស់គាត់នេះជាតំបន់ព្រៃសហគមន៍តែគាត់បានធ្វើការបកតបថា ដីព្រៃនេះជាតំបន់សហគមន៍របស់គាត់ ។ សូមបញ្ជាក់ថា នៅក្នុងឃុំមានិទ្ធបានរៀបចំគណៈកម្មការរួចហើយ ។

## យុទ្ធសាស្ត្រថ្មីសម្រាប់រដ្ឋបាលព្រៃឈើ និងសហគមន៍ ព្រមទាំងអាជ្ញាធរភូមិ -ឃុំ

កិច្ចប្រជុំបានឯកភាពគ្នានូវផែនការសកម្មភាពដូចខាងក្រោម:

១- រៀបចំកិច្ចប្រជុំមួយរវាងសហគមន៍ព្រៃឈើ និងរដ្ឋបាលព្រៃឈើព្រមទាំងអាជ្ញាធរភូមិ ឃុំមួយខែម្តងជាទៀងទាត់ ករណីពិសេសអាចធ្វើញឹកញាប់ ។

២-ផ្តល់ព័ត៌មានពីគ្នាទៅវិញទៅមករវាងសហគមន៍ព្រៃឈើ និងរដ្ឋបាលព្រៃឈើ ព្រមទាំងអាជ្ញាធរភូមិ ឃុំទាក់ទងទៅនឹងសកម្មភាពល្មើសព្រៃឈើ ។

៣-ធ្វើការផ្សព្វផ្សាយច្បាប់ និងពន្យល់ពីកាតព្វកិច្ចរបស់ខ្លួនតាមរយៈវគ្គហ្វឹកហ្វឺនស្នើសុំអោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលជួយសំរបសំរួល ។

៤-បន្តចូលរួមកិច្ចប្រជុំបណ្តាញសហគមន៍ព្រៃឈើថ្នាក់ខេត្ត ៣ខែម្តង ។

លោក **ឃុន ម៉ុនហេង** នាយរងផ្នែកព្រៃឈើសណ្តាន់ បានមានប្រសាសន៍ថា ដើម្បីឆ្លើយតបទៅនឹងវិវាទដែលចេះតែកើតឡើងគណៈកម្មការសហគមន៍គួរតែត្រូវបានបង្កើតនៅគ្រប់ឃុំដើម្បីងាយស្រួលក្នុងការដោះស្រាយវិវាទ ។

លោក **អ៊ុច ម៉ុនហ៊ី** អភិបាលរងស្រុកសណ្តាន់ ក៏បានគាំទ្រនូវការបង្កើតសហគមន៍ព្រៃឈើហើយក៏បានកោតសរសើរដល់ប្រជាពលរដ្ឋដែលមានឆន្ទៈក្នុងការការពារព្រៃឈើនៅក្នុងសហគមន៍ ។ ជាងនេះទៅទៀតលោកបានលើកអំពីចំណាប់លើ ៥ចំណុចមានដូចជា:

១- សហគមន៍ត្រូវមានភាពសុចរិត ( មិនក្រោមឥទ្ធិពលអ្វីមួយនោះទេ) ដែលការងារត្រូវបម្រើផលប្រយោជន៍រួម និងស្មោះត្រង់ ។

២- ជួយទប់ស្កាត់ការកាន់កាប់ដីព្រៃខុសច្បាប់ ។

៣- ចូលរួមពង្រឹងច្បាប់ដែលមានជាធរមាន ។

៤- ចូលរួមបង្កើតសហគមន៍ឱ្យបានលឿន និងសំណូមពរឱ្យរដ្ឋបាលព្រៃឈើជួយជ្រោមជ្រែង ។

៥- រាល់ការប្រជុំ សូមឱ្យជូនដំណឹងឱ្យស្រុកបានដឹងផង ដើម្បីស្រុកចាត់មន្ត្រីមកចូលរួម ។

កិច្ចប្រជុំបានប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ ដោយបានឯកភាពជាគោលការណ៍ក្នុងការពង្រឹងលើការទំនាក់ទំនង និងការសំរបសំរួលផ្តល់បច្ចេកទេស និងច្បាប់ក្នុងការដំណើរការរៀបចំបង្កើតសហគមន៍ព្រៃឈើ ។ ជាក់ស្តែងរដ្ឋបាលព្រៃឈើទាំងថ្នាក់ជាតិ ខណ្ឌ ផ្នែក និងសង្កាត់បានសន្យាថា នឹងធ្វើការគាំទ្រព្រមទាំងលើកទឹកចិត្តដល់សហគមន៍ អោយបង្កើតសហគមន៍ព្រៃឈើអោយកាន់តែលឿនដែលគំនិតនេះពីមុនមកមិនដែលមានទេ ។ ទន្ទឹមនឹងនោះអាជ្ញាធរដែនដី ជាពិសេសអភិបាលស្រុកសំណ្តាន់ និងក្រុមប្រឹក្សាឃុំក៏បានសំដែងនូវការគាំទ្រផងដែរ ។ អង្គការក្នុងស្រុកដែលជាដៃគូរនឹងធ្វើការតាមដានព្រមទាំងជំរុញអោយលទ្ធផលនៃកិច្ចប្រជុំនេះ ត្រូវបានយកទៅអនុវត្តតាមរយៈការផ្តល់ព័ត៌មាននៅឯកិច្ចប្រជុំបណ្តាញព្រៃឈើ និងចំការឈើដាំ ។

*អត្ថបទដោយដោយបណ្តាញព្រៃឈើ និងចំការឈើដាំនៃ*
*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*



សកម្មភាពអ្នកភូមិបានចូលរួមកិច្ចប្រជុំរវាងរដ្ឋាភិបាលព្រៃឈើ និងគណៈកម្មការសហគមន៍

# វគ្គបណ្តុះបណ្តាល ស្តីពីការដោះស្រាយទំនាស់ព្រៃឈើ និងចំការឈើដាំ

យោងតាមតម្រូវការជាក់ស្តែងរបស់សមាជិកបណ្តាញព្រៃឈើ និងចំការឈើដាំវគ្គបណ្តុះបណ្តាលមួយត្រូវបានរៀបចំឡើងរយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី ២៣-២៥ ខែឧសភា ឆ្នាំ២០០៧ នៅសាកលវិទ្យាល័យខេមរៈ សាខាខេត្តពោធិសាត់ ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលគឺបង្កើនសមត្ថភាពសមាជិកបណ្តាញដែលជាសកម្មជនព្រៃឈើ និងបុគ្គលិកអង្គការពីទស្សនៈវិធីសាស្ត្រ និងគោលការណ៍ក្នុងការសំរបសំរួលដោះស្រាយទំនាស់ដោយសកម្មអហិង្សា និងប្រសិទ្ធិភាព ។

វគ្គហ្វឹកហ្វឺនបានប្រព្រឹត្តណ៍ទៅរយៈពេលបីថ្ងៃ ដោយពីរថ្ងៃសិក្សាពីទ្រឹស្តី និងមួយថ្ងៃទៀត ធ្វើការទស្សនៈកិច្ចតំបន់ដែលមានទំនាស់ ។ តំបន់ដែលសិក្ខាកាមទស្សនៈកិច្ចគឺតំបន់សហគមន៍អន្សាចំប៉ក់ដែលមានទំនាស់ជាមួយក្រុមហ៊ុនភាពីម៉ិច និងតំបន់សហគមន៍ព្រៃឈើបង្កងឃ្មុំដែលមានទំនាស់ជាមួយយោធា ។

ក្នុងវគ្គហ្វឹកហ្វឺននោះសិក្ខាកាមបានលើកឡើងនូវលទ្ធផលរំពឹងមួយចំនួនដូចខាងក្រោម:

- ទទួលបានបទពិសោធន៍ថ្មីៗ
- ទទួលបានវិធីសាស្ត្រល្អៗក្នុងការដោះស្រាយទំនាស់
- ទទួលបានពត៌មានទាក់ទងនិងទំនាស់
- វិធីសាស្ត្រថ្មីក្នុងការបង្រៀន និង ផ្សព្វផ្សាយបន្តដល់សហគមន៍ និង ស្ថាប័នពាក់ព័ន្ធ
- ស្វែងយល់ពីយុទ្ធសាស្ត្រដោះស្រាយទំនាស់ប្រកបដោយប្រសិទ្ធិភាព
- មានសមត្ថភាពសំរបសំរួលដោះស្រាយទំនាស់
-ចេះធ្វើផែនការដោះស្រាយទំនាស់ ។ល ។

សិក្ខាកាមដែលបានអញ្ជើញចូលរួមមកពីខេត្តមួយចំនួនដូចជា ខេត្តកោះកុង កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ ប៉ៃលិន ក្រចេះ រតនៈគីរី និងរាជធានីភ្នំពេញ ដូចមានឈ្មោះខាងក្រោម:

| | |
|---|---|
| ១- កញ្ញា **សំ ស្រីណែត** | ២- លោក **មើប ញារ៉ា** |
| ៣- លោក **គិន សុខុន្ធី** | ៤- កញ្ញា **ពៅ ផល្លីន** |
| ៥- លោក **ម្ទុខ ចិន្តា** | ៦- កញ្ញា **សេក ដាវី** |
| ៧- លោក **សាន់ សុម៉េត** | ៨- លោក **ស៊ិន ថ្វន** |
| ៩- កញ្ញា **លុយ សារ៉េន** | ១០- លោក **ឆូ ទាសនា** |
| ១១- កញ្ញា **មីន គន្ធា** | ១២- កញ្ញា **ជួត ដាណែត** |

នៅក្នុងសកម្មភាពបណ្តុះបណ្តាល អ្នកសំរបសំរួលបានបញ្ចូលនូវវិធីសាស្ត្រមួយចំនួនដូចជា ការពន្យល់ទ្រឹស្តីដោយបង្ហាញតាមរយៈការបញ្ចាំងជាស្លាយ ការបំផុសគំនិត ការពិភាក្សាជាក្រុម ការធ្វើការបង្ហាញ ការសំដែង ករណីសិក្សា និងការធ្វើលំហាត់ ។ល ។ ខ្លឹមសារមេរៀនមានដូចខាងក្រោម:

- ល្បែងថាមពលទាក់ទងនឹងជំលោះព្រៃឈើ និងចំការឈើដាំ ។
- គោលគំនិតទូទៅនៃជំលោះផ្តោតលើព្រៃឈើ និងការដាំដើមឈើ ។
- លើកយកករណីសិក្សាចំនួន ៥ ( មណ្ឌលគីរី ស្ទឹងត្រែង ពោធិសាត់ កំពង់ធំ និងកោះកុង) ទាក់ទងនឹងបញ្ហាមេរៀនដែលជាបទពិសោធន៍ និងការផ្តល់អនុសាសន៍ ។
- ការវិភាគលើជំលោះដោយប្រើប្រាស់រចនាសម្ព័ន្ធ និងដ្យាក្រាមដើមឈើ ។




វគ្គបណ្តុះបណ្តាល ស្តីពីការដោះស្រាយទំនាស់ព្រៃឈើ និងចំការឈើដាំ

- ករណីសិក្សាក្នុងខេត្តពោធិ៍សាត់: ទាក់ទងនឹងបញ្ហាចំពោះមុខ មេរៀនដែលជាបទពិសោធន៍ និងភាពជោគជ័យ រៀបចំការងារចុះអនុវត្តនៅមូលដ្ឋាន ។
- ចុះមូលដ្ឋាននៅឃុំអន្សាចំបក់ក្រុមហ៊ុនសម្បទានដីភាគីម៉ិច និងសហគមន៍ព្រៃឈើបង្កងឃុំ ។
- ធ្វើបទបង្ហាញអ្វីដែលបានរៀនសូត្រពីសហគមន៍ និងការផ្តល់ជាអនុសាសន៍ ។
- វិធីសាស្ត្រនៃការចូលរួមទាក់ទងទៅនឹងការដោះស្រាយទំនាស់ព្រៃឈើ និងការដាំដើមឈើ ដោយប្រើប្រាស់វិធីសាស្ត្រការទំនាក់ទំនងសកម្ម និងអហិង្សា ។
- ការបង្កើតវិធីសាស្ត្រ និងផែនការជាយុទ្ធសាស្ត្រដើម្បីដោះស្រាយជំលោះលើករណីចំនួនប្រាំ ក្នុងករណីសិក្សាខាងលើដោយបង្កើតនូវ:
- បង្កើតគោលដៅ គោលបំណង ផែនការយុទ្ធសាស្ត្រ និងសកម្មភាព ព្រមទាំងថវិកា ។
- គោលគំនិតសំខាន់ៗ និងយន្តការទាក់ទងទៅនឹងវិធីសាស្ត្រក្នុងការដោះស្រាយទំនាស់ ។
- ទស្សនៈសម្បទានដីធ្លី និងការបែងចែកដីធ្លីនៅក្នុងប្រទេសកម្ពុជា ព្រមទាំងសក្តានុពលនៃទំនាស់ ។
- ការបង្កើតផែនការសកម្មភាពរបស់សិក្ខាកាម ដើម្បីដោះស្រាយជំលោះតាមរយៈអ្នកចូលរួមផ្ទាល់ ។
- ការសំយោគមេរៀន ការឆ្លើយតប និងការឆ្លុះបញ្ចាំងនៃវគ្គបណ្តុះបណ្តាល ។

ឆ្លងកាត់វគ្គសិក្សារយៈពេលបីថ្ងៃនេះ សិក្ខាកាមដែលមានវត្តមាននៅក្នុងវគ្គបណ្តុះបណ្តាលទាំងអស់បានទទួលនូវចំណេះដឹងមួយចំនួនដូចខាងក្រោម តាមរយៈការវាយតំលៃវគ្គចុងក្រោយ:

- យល់ដឹងពីនិយមន័យទូទៅលើទំនាស់ទាក់ទងទៅនឹងព្រៃឈើ និងចំការឈើដាំ ។
- បានយល់ដឹងអំពីមូលហេតុនៃទំនាស់ វិសាលភាពនៃទំនាស់ តាមការវិភាគទំនាស់តាមបែបដើមឈើ ។
- បានយល់ដឹងពីទំនាក់ទំនងនៃទំនាស់ដោយប្រើផ្សាក្រាមក្នុងការវិភាគ ។
- ចេះធ្វើផែនការសំរបសំរួលទំនាស់ ដោយធ្វើការកំណត់នូវអ្នកពាក់ព័ន្ធផ្ទាល់ និងប្រយោល អ្នកដែលមានឥទ្ធិពល និងអ្នកដែលមានប្រសិទ្ធិភាពក្នុងការសំរបសំរួលដោះស្រាយទំនាស់ ។
- ទទួលបានបទពិសោធន៍ជាយុទ្ធសាស្ត្រក្នុងការដោះស្រាយទំនាស់តាមរយៈបទបង្ហាញពីករណីសិក្សាបន្ថែម ស្តីអំពីជំលោះរវាងសហគមន៍ព្រៃឈើជាមួយនឹងទាហ៊ាន និងរវាងសហគមន៍ជាមួយក្រុមភាពពីម៉ិច ។

ចុងបញ្ចប់នៃវគ្គហ្វឹកហ្វឺន សិក្ខាកាមទាំងអស់បានធ្វើផែនការមួយសំរាប់យកបទពិសោធន៍ពីការសិក្សានោះទៅអនុវត្តជាក់ស្តែង ។ ផែនការនោះនឹងត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញ នៅឯកិច្ចប្រជុំបណ្តាញព្រៃឈើ និងចំការឈើដាំលើកក្រោយ ។

*អត្ថបទដោយដោយបណ្តាញព្រៃឈើ និងចំការឈើដាំនៃ*
*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

## ពពុះទឹកមានសារធាតុពុលនៅខាងលើទន្លេសេសាន

ក្រុមស៊ើបអង្កេតអន្តរជាតិ

ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ២០០៧

ពពុះទឹកមានសារធាតុពុលនៅក្នុងអាងទឹកធំបំផុតទីពីររបស់ប្រទេសវៀតណាមពាក់ព័ន្ធទៅនឹងការបង្កឱ្យមានជម្ងឺដល់ប្រទេសកម្ពុជាដែលនៅចុងខ្សែទឹក អាងស្តុកទឹកថ្មីអាចបង្កើតឱ្យមានពពុះទឹកមានជាតិពុលបានក្នុងរយៈពេលដែលមានការស្តុកទឹកចាប់ពី ៥ ទៅ ១០ឆ្នាំ រហូតមកដល់ពេលនេះ វាស្មើរតែ ១០ឆ្នាំទៅហើយបន្ទាប់ពីអ្នកស្រុកដែលរស់នៅភាគខាងជើងនៃប្រទេសកម្ពុជាបានរាយការណ៍ជាលើកទីមួយថាទឹកនៅក្នុងទន្លេសេសានមានខ្លិនស្អុយ ហើយបានកំពុងតែបង្កឱ្យពួកគេមានជម្ងឺមកនោះ ។ អ្នកជំនាញន័រឌីក (Nordic) បានកត់សម្គាល់ឃើញនូវបញ្ហានោះថា ពពុះទឹកពណ៌ខៀវដែលមានជាតិពុលនៅក្នុងអាងទឹកដ៏មួយក្នុងប្រទេសវៀតណាមនៅផ្នែកខាងលើនៃទន្លេសេសានដែលមានចម្ងាយប៉ុន្មានជា ៧០គម ពីព្រំដែនកម្ពុជា វៀតណាម ។

ដោយយោងទៅលើការវាយតម្លៃពីផលប៉ះពាល់មកលើបរិស្ថានដែលបានរៀបចំឡើងដោយវិទ្យាស្ថានន័រវ៉េ (Norwegian) សម្រាប់ការស្រាវជ្រាវទឹក និងក្រុមផ្តល់យោបល់ផ្នែកទឹក Nordic ឈ្មោះ SWECO Groner បានបង្ហាញថា: "តាមរយៈការធ្វើវិភាគនានាបានបញ្ជាក់ថា មានពូជជាច្រើនប្រភេទនៃជាតិពុលដែលបង្កើតពពុះទឹកពណ៌បៃតងខៀវដែលមាននៅក្នុងអាងទឹក (យ៉ាលី)" ហើយពពុះទឹកនោះឯងបានបង្កឱ្យមាន "រោគសញ្ញាដូចគ្នាបេះបិទ" ទៅនឹងអ្វីដែលបានរាយការណ៍ដោយប្រជាជនកម្ពុជាដែលរស់នៅផ្នែកខាងក្រោមនៃទន្លេសេសាន ។

នៅក្នុងរវាងឆ្នាំ១៩៩៨ និងឆ្នាំ២០០០ ទំនប់ទឹកយ៉ាលីដែលគេកសាងអស់ទឹកប្រាក់ចំនួន ១,០០០,០០០,០០០ ដុល្លារសហរដ្ឋអាមេរិកនោះ បានជន់លិចផ្ទៃដីវាល និងដីព្រៃចំនួន ៦៥គម² បង្កើតឱ្យមានល័ក្ខខ័ណ្ឌសារធាតុចិញ្ចឹមដ៏សម្បូរបែបសម្រាប់ពពួកពពុះទឹកដែលមានខ្លិនស្អុយ ។

"វាហាក់មានភាពដូចគ្នាបេះបិទ" នៅក្នុងកំឡុង ២-៣ឆ្នាំដំបូង (ពេលដែលអាងទឹកយ៉ាឡៃកំពុងតែស្តុកទឹក) មានឧប្បត្តិហេតុជាច្រើនបានកើតឡើងដោយសារតែពពុះទឹកពណ៌បៃតងខៀវដែលបាន (បង្ក) ឱ្យគុណភាពទឹកមានបញ្ហានៅក្នុងទន្លេសេសាន ក្នុងខេត្តរតនគិរី ស្ទឹងត្រែង ហើយដែលបង្កឬជំរុញឱ្យមានបញ្ហាផ្នែកសុខភាពសត្វ និងមនុស្សនៅក្នុងកំឡុងឆ្នាំ២០០០ ។

សេចក្តីរាយការណ៍នោះបានបញ្ជាក់ថា រោគសញ្ញាដែលកើតមានចំពោះប្រជាជនរស់នៅតាមដងទន្លេសេសានក្នុងខេត្តរតនគិរីមានដូចជាជម្ងឺឈឺក្បាល វិលមុខធីងធោង និងបញ្ហាជាច្រើនដែលពាក់ព័ន្ធផ្លូវដង្ហើមដែលទំនងជាបង្កឡើងដោយពពុះទឹកដែលផ្ទុកទៅដោយសារធាតុម្យ៉ាងដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធខួរក្បាលដែលមានឈ្មោះថាមីក្រូស៊ីស្ទីន (Microcystin) ។

គេបានធ្វើពិសោធន៍នៅក្នុងអាងទឹកយ៉ាលី និងនៅទន្លេភាគខាងក្រោមនៅក្នុងរដូវភ្លៀងនៅចុងឆ្នាំ២០០៥ បានរកឃើញបណ្តុំពពុះទឹកមានជាតិពុលនោះថាវាមិនអាចបង្កការគំរាមកំហែងដល់សុខភាពឆាប់ពេកនោះទេ ។ ទោះជាយ៉ាង

ណាក៏ដោយ របាយការណ៍នោះបានដាស់តឿនថា កំណើនពពុះទឹកទាំងនោះអាចរាលដាលក្នុងរយៈពេល ២-៣ថ្ងៃ ហើយថា ការប្រមូលផ្តុំដ៏ខ្ពស់ទំនងជានៅក្នុងរដូវប្រាំង ។

របាយការណ៍នោះក៏បានឱ្យជាយោលបល់ថា គេត្រូវតែធ្វើពិសោធន៍ទៅលើអាងទឹកយ៉ាលីនោះរៀងរាល់ ១៤ថ្ងៃម្តង នៅក្នុងរដូវប្រាំង ហើយបានដាស់តឿនថា ការរីកឡើងនៃពពុះទឹកនោះអាចនឹងកើតមាននៅក្នុងអាងទឹកថ្មីៗទៀតនៅតាមបណ្តោយទន្លេសេសាន បន្ទាប់ពីបានស្តុកទឹកចាប់ពី ៥-១០ឆ្នាំមក ។

យ៉ាងហោចណាស់ក៏មានប្រជាជនប្រម៉ាណជា ២៨,០០០នាក់រស់នៅភាគខាងជើងប្រទេសកម្ពុជាបានពឹងផ្អែកដោយផ្ទាល់ទៅលើទន្លេសេសានដូចជា ទឹកបរិភោគ ទឹកងូត ការធ្វើនេសាទ និងការចិញ្ចឹមត្រីជាដើម ។

នៅក្នុងប្រទេសចិន ពពុះទឹកបៃតងខៀវ ដែលមានជាតិពុលនេះ បានរីករាលដាលដល់បឹងធំបំផុតពីររបស់ប្រទេសចិននៅក្នុងឆ្នាំនេះដែលបានបង្ខំឱ្យប្រជាជនរស់នៅក្នុងខេត្ត ជាងហ្សូ បិទទុយោផ្គត់ផ្គង់ទឹកដ៏កខ្វក់នោះចោល ។ មន្ទីរសុខាភិបាលបានជម្រុញឱ្យអាជ្ញធររដ្ឋាភិបាលធ្វើការត្រួតពិនិត្យទឹកដែលកខ្វក់នោះជាប្រចាំម៉ោង ហើយធ្វើការណែនាំដល់អ្នករស់នៅទីនោះកុំឱ្យប្រើប្រាស់ទឹកនោះដោយចាំរហូតដល់ជាតិពុលនោះបាត់បង់សិន ។

មេរោគពណ៌ខៀវ (Cyanobacteria) គឺជាឈ្មោះវិទ្យាសាស្ត្រ សម្រាប់ពពុះទឹកពណ៌បៃតងខៀវឬ "ស្រះកខ្វក់" ដែលបានបញ្ចេញចោលនូវសារជាតិពុលជាច្រើនប្រភេទ ដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ថ្លើម (hepatoto- xin) ឬប្រព័ន្ធសរសៃប្រសាទ (neurotoxins) ពេលបានបរិភោគវាចូល ឬជាធម្មតាវាអាចបង្កឱ្យរមាស់ បន្ទាប់ពីងូតទឹករួច ។ ការបំពុលថ្លើមអាចចំណាយពេលជាច្រើនម៉ោងឬថ្ងៃទើបបង្កើតជារោគសញ្ញាអាចបង្កឱ្យមានការឈឺចាប់ក្នុងពោះជម្ងឺរាគរូស ក្អួតចង្អោរសម្រាប់មនុស្ស ហើយអោយធ្វើឱ្យសត្វស្លាប់ផងដែរ ។ វាក៏បានបង្កើតឱ្យមានជម្ងឺថ្លើមផ្សេងៗទៀតផងដែរដូចជា រលាកថ្លើមដែលផលប៉ះពាល់នេះអាចបង្កឱ្យបាត់បង់ជីវិតបាន ។

ការសិក្សាអំពីទឹកលើកដំបូង ដែលផ្តត់ផ្គង់ហិរញ្ញវត្ថុដោយប្រទេសកាណាដា ប្រទេសន័រវ៉េ និងប្រទេសស្វីស ខកខានមិនបានក្រើនរំលឹកប្រភពវារីអគ្គិសនីរបស់វៀតណាមអំពីហានិភ័យចំពោះសុខភាព និងបរិស្ថានពាក់ព័ន្ធទៅនឹងការសាងសង់ទំនប់របស់ខ្លួននៅលើទន្លេសេសានដែលជាដៃទន្លេមេគង្គហូរចុះពីទំនាបកណ្តាលរបស់ប្រទេសវៀតណាមកាត់តាមភាគឦសាននៃប្រទេសកម្ពុជានោះឡើយ ។

នៅក្នុងឆ្នាំ២០០០ ការបើកទឹកយ៉ាងគំហុកពីទំនប់ទន្លេយ៉ាលីបានសម្លាប់ប្រជាជនកម្ពុជាជាង ៣០នាក់ ដែលរស់នៅចុងទឹកក្នុងប្រទេសកម្ពុជាហើយបានហូរនាំយកទូកឧបករណ៍នេសាទនឹងជន់លិចដំណាំរបស់ប្រជាជនអស់យ៉ាងច្រើន ។ អ្នកគ្រប់គ្រងទំនប់វារីអគ្គិសនីប្រទេសវៀតណាមមិនទាន់បានផ្តល់ប្រាក់សំណងដល់ប្រជាជនទាំងនោះ និងការខូចខាតនានានៅឡើយទេ ទោះបីជាមានការតវ៉ាពីរសំណាក់ប្រជាជនដែលរស់នៅទីនោះ និងមន្ត្រីរបស់ប្រទេសកម្ពុជាយ៉ាងណាក៏ដោយ ។

សម្រាប់ព័ត៌មាន និងរូបថតបន្ថែម សូមទំនាក់ទំនងតាមអាស័យដ្ឋានដូចខាងក្រោម :


លោកស្រី Grainne Ryder

ជាប្រធានផ្នែកគោលនយោបាយ

ក្រុមស៊ើបអង្កេតអន្តរជាតិនៃអង្គការ Probe International

ទីក្រុងតូរ៉ាន់តូ ប្រទេសកាណាដា

ទូរស័ព្ទ : ១ ៤១៦ ៩៦៤ ៩២២៣ (extension ២២៨)

អ៊ីមែល : GrainneRyder@nextcity.com


*អត្ថបទដោយក្រុមស៊ើបអង្កេតអន្តរជាតិគឺជាក្រុមប្រជាជនដែលមានមូលដ្ឋាននៅក្នុងទីក្រុងតូរ៉ាន់តូធ្វើការត្រួតពិនិត្យពីប្រសិទ្ធភាពជំនួយរបស់ប្រទេសកាណាដា និងក្រុមហ៊ុនមួយចំនួននៅក្នុងប្រទេសកំពុងអភិវឌ្ឍទៅលើបរិស្ថាន និងសេដ្ឋកិច្ច ។*

---

# មជ្ឈមណ្ឌលព័ត៌មានដីធ្លី (LIC) នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

## ១.តើមជ្ឈមណ្ឌលព័ត៌មានដីធ្លីគឺជាអ្វី?

មជ្ឈមណ្ឌលព័តិមានដីធ្លីគឺជាគំរោងមួយថ្មីស្ថិតនៅក្នុងកម្មវិធីដីធ្លី និងជីវភាពរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia) ដើម្បីជួយគាំទ្រទៅដល់ដំណើរការរបស់គំរោងដីធ្លី និងគំរោងព្រៃឈើ ។

ដោយមើលឃើញថា ការចែករំលែកព័តិមានទៅវិញទៅមកដើរតួនាទីយ៉ាងសំខាន់ និងមិនអាចខ្វះបាននៅក្នុងការធ្វើយុទ្ធសាស្ត្រតស៊ូមតិដើម្បីឈានទៅរកការអភិវឌ្ឍន៍សង្គម និងដោយម្យ៉ាងវិញទៀត ប្រទេសកម្ពុជានៅមានភាពខ្វះចន្លោះច្រើន និងទន់ខ្សោយក្នុងការចែករំលែកព័តិមានរវាងបណ្តាអង្គការមិនមែនរដ្ឋាភិបាល រវាងអង្គការ និងភ្នាក់ងាររដ្ឋាភិបាល រវាងអង្គការ និងសហគមន៍... ។ល ។ ទើបវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាបានសំរេចបង្កើតគំរោងនេះឡើងដោយបានធ្វើការសិក្សាស៊ីជំរៅពីសារៈប្រយោជន៍របស់គំរោងនេះ និងកំណត់ពីបញ្ហាអទិភាពដែលគំរោងនេះនឹងធ្វើការគាំទ្រដោយមានទិសដៅរួមគឺៈ សហការគ្នាដើម្បីធ្វើការប្រមូលទិន្នន័យ ឬព័តិមានអំពីបញ្ហាដីធ្លី និងព្រៃឈើដើម្បីយកទៅធ្វើការពិភាក្សាគ្នាជាសាធារណៈរកយុទ្ធសាស្ត្រគ្រប់គ្រង និងកិច្ចការរដ្ឋបាលផ្សេងៗទៅលើបញ្ហាដីធ្លី និងធនធានធម្មជាតិ ។

គំរោងនេះ នឹងធ្វើការជិតស្និទ្ធជាមួយគំរោងបួនផ្សេងទៀតនៅក្នុងកម្មវិធីដីធ្លី និងជីវភាពរួមជាមួយនឹងបណ្តាញរបស់គំរោងនិមួយៗពោលគឺគំរោងដីធ្លីគំរោងព្រៃឈើ និងចំការឈើដាំគំរោងសិទ្ធិជនជាតិដើមភាគតិច និងគំរោងរុះរើលំនៅដ្ឋានតាមរយៈការបែងចែកព័តិមានទៅវិញទៅមក ។

## ២.តើមជ្ឈមណ្ឌលព័ត៌មានដីធ្លីមានគោលបំណងអ្វី?

រាល់សកម្មភាពទាំងឡាយដែលមជ្ឈមណ្ឌលដីធ្លីអនុវត្តឡើងគឺមានគោលបំណងទីមួយដើម្បីជួយពង្រឹងទៅដល់ការប្រមូលទិន្នន័យអោយមានប្រសិទ្ធិភាពទៅលើបញ្ហាដីធ្លី និងព្រៃឈើ ព្រមទាំងជួយពង្រឹងទៅដល់ដំណើរការផលិតនិងវិភាគទិន្នន័យ ។ គោលបំណងទីពីរដើម្បីប្រមូលទិន្នន័យពីប្រភពព័ត៌មានផ្សេងៗទៀត និងទីបីអោយទិន្នន័យដែលបានវិភាគហើយត្រូវបានប្រើប្រាស់ដើម្បីជាយុទ្ធសាស្ត្រមួយសំរាប់ធ្វើការតស៊ូមតិ ។

## ៣.តើមជ្ឈមណ្ឌលព័ត៌មានដីធ្លីមានសកម្មភាពអ្វីខ្លះ?

សកម្មភាពចំបងបួនធំៗរបស់មជ្ឈមណ្ឌលព័ត៌មានដីធ្លី គឺទីមួយការជួយពង្រឹងសមត្ថភាពដល់សមាជិកបណ្តាញរបស់គំរោងតាមរយៈការផ្តល់ការបណ្តុះបណ្តាលទៅលើវិធីសាស្ត្រអង្កេត ចុះប្រមូលទិន្នន័យ វិធីសាស្ត្រស្រាវជ្រាវ និងការវិភាគទិន្នន័យ ។ សកម្មភាពសំខាន់ទីពីរគឺ ការគ្រប់គ្រងព័ត៌មានបញ្ហាដីធ្លីតាមរយៈប្រព័ន្ធកំព្យូទ័រ ។ សកម្មភាពចំបងទីបីគឺធ្វើការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រទៅលើបញ្ហាអ្វីមួយ និងទីបួនគឺ ការចុះអង្កេតដើម្បីប្រមូលព័ត៌មានពីព្រឹត្តការណ៍អ្វីមួយដែលបានកើតឡើងដែលពាក់ព័ន្ធទៅនឹងបញ្ហាដីធ្លី ព្រៃឈើ ការរុះរើលំនៅដ្ឋាន និងសិទ្ធិរបស់ជនជាតិដើមភាគតិច ។

## ៤.តើមជ្ឈមណ្ឌលព័ត៌មានដីធ្លីដំណើរការយ៉ាងដូចម្តេច?

រូបខាងលើគឺបានបង្ហាញយ៉ាងច្បាស់ពីរចនាសម្ព័ន្ធនៃដំណើរការរបស់មជ្ឈមណ្ឌលព័ត៌មានដីធ្លី ពោលគឺជាកន្លែងដែលផ្ទុកនូវរាល់ព័ត៌មានទាំងឡាយដែលទទួលបានពីអង្គការដៃគូ បណ្តាញ សហគមន៍ ភ្នាក់ងាររដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ និងជាកន្លែងសំរាប់ដំណើរការផលិតទិន្នន័យទាំងឡាយដែលទទួលបាននោះសំរាប់ជួយគាំទ្រដល់ដំណើរការតស៊ូមតិរបស់ពួកគេវិញ ។

រាល់ព័ត៌មានទាំងអស់នឹងត្រូវធ្វើការសិក្សាបន្ថែមតាមរយៈការចុះទៅស៊ើបអង្កេត និងធ្វើការស្រាវជ្រាវដែលជាដំណាក់កាលទីមួយបន្ទាប់មកនឹងបញ្ជូនទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលរួមមាន ការរៀបចំចងក្រងឯកសារទាំងនោះ ការវិភាគ និងសរសេររបាយការណ៍ដែលជាដំណាក់កាលទីពីរ ហើយដំណាក់កាលចុងក្រោយគឺការបែងចែកព័ត៌មាន និងទិន្នន័យនោះទៅអ្នកប្រើប្រាស់ ។

**សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង:**

**លោក ហិប សុខាន់ណារ៉ូ**

អ៊ីម៉ែល: sokhannaro@ngoforum.org.kh

ទូរស័ព្ទ: ០២៣ ២១៤ ៤២៩ ភ្ជាប់បន្ត ១១១


ការិយាល័យមជ្ឈមណ្ឌលព័ត៌មានដីធ្លី នៃ
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា



# លទ្ធផលជាផ្លែផ្កាដែលទទួលពីវេទិកាសាធារណៈស្តីពីឥទ្ធិពលថ្នាំកសិកម្មទៅលើសុខភាពមនុស្ស សត្វ និងបរិស្ថាន ដែលជំរុញឱ្យស្ថាប័នពាក់ព័ន្ធនានាត្រូវអនុវត្តន៍បន្ត

វេទិកាសាធារណៈស្តីពី **ឥទ្ធិពលថ្នាំកសិកម្មទៅលើសុខភាពមនុស្ស-សត្វ និង បរិស្ថាន** ត្រូវបានប្រារព្ធធ្វើឡើងនៅសាលប្រជុំគណៈកម្មាធិការប្រតិបត្តិគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ ក្រោមកិច្ចសហការរវាងមន្ទីរកសិកម្មខេត្ត និងសមាជិកបណ្តាញកាត់បន្ថយថ្នាំកសិកម្មនៅកម្ពុជាដូចជា: NGO Forum, CD Cam, EB, Srer Khmer, Bantey Srei, RAHDO, MB, PNKS, ADIFE, CWS, EPDO ដោយមានការជួយឧត្ថមពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum on Cambodia) ប្រព្រឹត្តទៅរយៈពេលមួយថ្ងៃគឺថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧។ វេទិកានេះមានការចូលរួមពីមន្ទីរស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត អង្គការក្នុងតំបន់ និងកសិករដែលអញ្ជើញមកពីខេត្តបន្ទាយមានជ័យ, បាត់ដំបង, ស្វាយរៀង, សៀមរាប និងកំពង់ធំ។ វេទិកាសាធារណៈនេះបានផ្តល់នូវកិច្ចពិភាក្សាដើម្បីស្វែងរកដំណោះស្រាយរួមមួយរវាងកសិករ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលនានាក្នុងការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកដើម្បីរកចំណុចអភិវឌ្ឍន៍សង្គមជាតិ និងការកែប្រែជាវិជ្ជមាន។

## សមាសភាពអ្នកចូលរួមក្នុងវេទិកាសាធារណៈនៅខេត្តបន្ទាយមានជ័យ

ជាលទ្ធផលនៅក្នុងវេទិកាសាធារណៈនេះ យើងបានដំណើរការទៅប្រកបដោយលទ្ធផលដែលគួរឱ្យមោទនៈ និងពោពេញដោយភាពកក់ក្តៅ។ វេទិកានេះមានអ្នកចូលរួមមកពីមន្ទីរពាក់ព័ន្ធជុំវិញខេត្ត អង្គការក្នុងតំបន់ និងកសិករសរុបចំនួន ១៣០នាក់ ដែលទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងប្រចះត្រចង់ និងជាអនុសាសន៍មួយទៅរាជរដ្ឋាភិបាល ដើម្បីគិតគូរស្វែងរកដំណោះស្រាយសំរាប់ប្រជាជន និងប្រទេសជាតិទាំងមូល។ គួរបញ្ជាក់ដែរថា នៅក្នុងវេទិកាសារធាណៈនេះ យើងទទួលបានសំណូមពរ និងអនុសាសន៍មួយចំនួនដូចខាងក្រោម។

### សំណូមពររបស់អ្នកចូលរួម:

១. សំណូមពរដល់គ្រប់ស្ថាប័នពាក់ព័ន្ធជួយទប់ស្កាត់ និងផ្សព្វផ្សាយដល់កសិករឱ្យយល់ដឹងពីផលប៉ះពាល់របស់ថ្នាំកសិកម្ម និងសូមកសិករអនុវត្តន៍តាមការផ្សព្វផ្សាយរបស់អង្គការមិនមែនរដ្ឋាភិបាល។

២. សូមចូលរួមទាំងអស់គ្នាក្នុងការកាត់បន្ថយថ្នាំកសិកម្មនេះដើម្បីសុខភាព និងបរិស្ថានរបស់ប្រជាជន និងបរិស្ថានរបស់សង្គមជាតិយើង។

៣. សូមឱ្យធ្វើពិសោធន៍ដោយផ្ទាល់ដៃ ទើបប្រសើរ កុំជឿគេងាយៗ។

៤. សូមផ្តាំថាត្រូវការពារខ្លួន នៅពេលដែលសំរេចចិត្តប្រើប្រាស់ថ្នាំកសិកម្ម ដោយមានពាក់ម៉ាស់ អាវដៃវែង ស្រោមដៃ ហើយកុំជឿគេថាថ្នាំកសិកម្មមិនពុលនោះឱ្យសោះ។

### អនុសាសន៍ដែលទទួលពីអ្នកចូលរួម:

១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង ជំរុញឱ្យមានការបិទផ្លាក និងបកប្រែស្លាកសញ្ញាជាភាសាខ្មែរធំៗនៅលើដបថ្នាំកសិកម្ម និងសំភារៈកសិកម្ម។

២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង ជំរុញការចុះបញ្ជីការរាល់សំភារៈកសិកម្ម។

៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង ត្រូវអញ្ជើញអាជីវករមកបណ្តុះបណ្តាលអំពីការធ្វើអាជីវកម្ម និងការទុកដាក់។

៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង ណែនាំអាជីវករ និងមិនលើកទឹកចិត្តនូវការទិញថ្នាំរត់ពន្ធ។

៥. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង លើកទឹកចិត្តកសិករក្នុងការទិញថ្នាំណាដែលមានសរសេរជាអក្សរខ្មែរ។



សិក្ខាកាមចូលរួមក្នុងវេទិកាសាធារណៈ នៅខេត្តបន្ទាយមានជ័យ

៦. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង និងអង្គការមិនមែនរដ្ឋាភិបាល ជំរុញឱ្យមានការប្រើប្រាស់ថ្នាំរុក្ខជាតិ និងផ្សព្វផ្សាយដល់តំបន់ជនបទ ។

៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបន្ត និងជំរុញការផ្សព្វផ្សាយពីផលប៉ះពាល់ដែលបណ្តាលមកពីថ្នាំកសិកម្មដល់ប្រជាជននៅតាមតំបន់ជនបទដាច់ស្រយាល ។

៨. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង ត្រូវតែទប់ស្កាត់ការនាំចូលដោយពង្រឹងមាត់ទ្វារសេដ្ឋកិច្ច ។

៩. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង និងអង្គការមិនមែនរដ្ឋាភិបាល ជំរុញឱ្យកសិករដាំដំណាំបង្វិល ដំណាំឆ្លាស់ និងប្រព័ន្ធកសិកម្មនៅជុំវិញផ្ទះ ។

១០.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង ការចុះបញ្ជីការថ្នាំកសិកម្ម ។

១១.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង គួរតែរៀបចំអនុក្រឹត្យឱ្យទៅជាព្រះរាជក្រឹត្យ(ច្បាប់) ។

១២.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង បញ្ចូលគំរោងកាត់បន្ថយថ្នាំកសិកម្មទៅក្នុងផែនការមេរបស់រាជរដ្ឋាភិបាល ។

១៣.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង និងក្រសួងពាណិជ្ជកម្មគួរចាត់វិធានការទប់ស្កាត់ការរត់ពន្ធថ្នាំកសិកម្ម និងរៀបចំការចុះបញ្ជីការឱ្យបានត្រឹមត្រូវ ។

*អត្ថបទដោយលោកស្រី **ម៉ែន វណ្ណារី** មន្ត្រីគំរោងកាត់បន្ថយថ្នាំកសិកម្មនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា*

---

## បញ្ហាថ្នាំកសិកម្ម និងជីវភាពកសិករនៅតាមតំបន់ជនបទ

បច្ចុប្បន្នកសិករកម្ពុជាបានងាកទៅរកការអនុវត្តន៍កសិកម្មទំនើបតាមរយៈការប្រើប្រាស់ជីគីមី ថ្នាំកសិកម្ម និងគ្រាប់ពូជទំនើប ។ កសិកម្មគីមីបានជួយធ្វើឱ្យទិន្នផលដំណាំរបស់កសិករយើងកើនឡើង ប៉ុន្តែការកើនឡើងនោះមិនមាននិរន្តរភាពនោះទេ គឺវាកើនឡើងតែរយៈពេលខ្លីមួយប៉ុណ្ណោះ ហើយវាបានផ្តល់នូវបញ្ហាជាច្រើនក្នុងរយៈពេលដ៏យូរអង្វែងដូចជា ផលប៉ះពាល់សុខភាពទាំងកសិករទាំងអ្នកប្រើប្រាស់ និងធ្វើឱ្យការចំណាយរបស់កសិករកាន់តែខ្ពស់ ប៉ុន្តែទទួលនូវប្រាក់ចំណូលក្នុងកំរិតមួយដ៏ទាប ។ ដំណាំស្រូវជាដំណាំស្បៀងមួយសំខាន់បំផុតនៃប្រទេសកម្ពុជាព្រោះមានប្រជាជនប្រមាណ ៨០% ជាកសិករដែលពឹងផ្អែកលើវិស័យកសិកម្ម ជាពិសេសក្នុងការដាំដុះដំណាំស្រូវ ។ កសិករធ្វើការដាំដុះដំណាំស្រូវពឹងផ្អែកទៅលើទឹកភ្លៀងជាងពឹងផ្អែកទៅលើប្រព័ន្ធស្រោចស្រព ទន្ទឹមនឹងនោះដែរការងារដាំដុះក៏ជួបប្រទះនូវបញ្ហាមួយចំនួនដូចជា: កង្វះបច្ចេកទេសដាំដុះ ទីផ្សារលក់ផលិតផលកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ កត្តាសត្វល្អិតចង្រៃបំផ្លាញដំណាំ កង្វះពូជធន់ទ្រាំ ជាពិសេសជំងឺ និងសត្វល្អិត ។ នៅក្នុងប្រទេសកម្ពុជាយើងបើតាមការបាន់ប្រមាណមានការចំណាយផ្ទាល់ទៅលើការប្រើប្រាស់ថ្នាំកសិកម្មក្នុងមួយឆ្នាំលើផលិតកម្មដំណាំមានប្រមាណជា ២០លានដុល្លាសហរដ្ឋអាមេរិក ។រីឯគិតជាមធ្យមក្នុងមួយគ្រួសារកសិករចំណាយថវិកាអស់ចំនួនប្រហែល ៧៦៩ដុល្លាក្នុងមួយឆ្នាំទៅលើការទិញថ្នាំកសិកម្ម ។ ថ្នាំកសិកម្មដែលលក់នៅលើទីផ្សារមានស្លាកសញ្ញាជាភាសាបរទេសដែលធ្វើឱ្យកសិករកម្ពុជាយើងពុំអាចអានបាននូវការណែនាំពីការប្រើប្រាស់ថ្នាំកសិកម្មឱ្យបានត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស ។ ចំពោះស្លាកសញ្ញាថ្នាំកសិកម្មមានជាភាសាផ្សេងៗ: ភាសាថៃ ៣៧. ៦% ភាសាចិន ១.៦% ភាសាមាឡេស៊ី ០.២% ភាសាអង់គ្លេស ៧.៦% ភាសាវៀតណាម ៤៨.២% និងសរសេរជាភាសាខ្មែរមានត្រឹមតែ ២.៥% ប៉ុណ្ណោះ ដែលក្រុមហ៊ុនមួយចំនួនបាននាំចូលមកបិទផ្លាកជាថ្មីនៅឆ្នាំ១៩៩៩ នៅកម្ពុជា ។ ម្យ៉ាងវិញទៀត នៅលើដប និងកញ្ចប់ថ្នាំកសិកម្មភាគច្រើនដែលមិនបានបោះត្រាបញ្ជាក់ពីថ្ងៃ ខែ ឆ្នាំផលិត និងផុតកំណត់ការប្រើប្រាស់ ។ ក្នុងចំណោមថ្នាំកសិកម្មទាំងនោះមានតែថ្នាំកសិកម្មដែលនាំចូលពីប្រទេសវៀតណាមទេដែលបានចុះថ្ងៃ ខែ ឆ្នាំផលិត និងផុតកំណត់ការប្រើប្រាស់បានត្រឹមត្រូវ ។ ជាលទ្ធផលការនាំចូលខុសច្បាប់ពីប្រទេសជិតខាងមានកំរិតខ្ពស់តាមការប៉ាន់ប្រមាណថា ខ្ពស់បំផុតត្រឹម ៤០% និងទាបបំផុតត្រឹម ២០% នៃថ្នាំកសិកម្ម គឺជាផលិតផលនាំចូលដែលមានការអនុញ្ញាតិជាផ្លូវការ ។ ថ្នាំកសិកម្មត្រូវបានគេយកមកតាំងលក់ជាមួយទំនិញផ្សេងៗមានដូចជាចំណីអាហារកំប៉ុង គ្រឿងភេសជ្ជៈ ឧបករណ៍កសិកម្ម និងនេសាទ ប្រដាប់ប្រដាប្រើប្រាស់ក្នុងផ្ទះបាយ និងតាំងលក់ជាមួយជីគីមី និងគ្រាប់ពូជ ទន្ទឹមនឹងនោះមានកន្លែងមួយចំនួនមានតាំងលក់ជាមួយថ្នាំពេទ្យផងដែរ ។ គេឃើញមានការដាក់តាំងលក់ថ្នាំកសិកម្មជាមួយជីគីមី គ្រឿងដែកគ្រឿងក្រអូប និងភេសជ្ជៈ ម្យ៉ាងទៀតដោយសារតូបមានលក្ខណៈតូចចង្អៀតថ្នាំកសិកម្មមួយចំនួនត្រូវបានដាក់លក់ជាមួយទំនិញផ្សេងៗដែលមានគេតាំងលក់ដែរដោយគាត់យល់ថា វាមានគំរបបិទជិត និងវេចខ្ចប់បានត្រឹមត្រូវ ហើយពួកគេគិតថាវាមិនអាចហើរឬជ្រៀបចេញបានឡើយ ។ ប្រជាកសិករកម្ពុជាដែលប្រើប្រាស់សារធាតុគីមី សារធាតុបំប៉ន និងចំណីសត្វដែលមានសារធាតុគីមីត្រូវបង្ខំចិត្តទៅចងការប្រាក់ពីស្ថាប័នឥណទាន និងឈ្មួញឯកជនមួយចំនួន ។ ទោះបីជាកសិករខិតខំបង្កើនការខ្ចីបំណុលពីខាងក្រៅដើម្បីទិញសារធាតុគីមីដូចជា ជីគីមី និងថ្នាំកសិកម្មក្នុងការប្រកបរបរកសិកម្ម និងទទួលបានកសិផលមួយសមគួរយ៉ាងណាក៏ដោយ ក៏ជីវភាពកសិករមិនមានភាពប្រសើរឡើងដែរ តែផ្ទុយទៅវិញគាត់កំពុងធ្លាក់ខ្លួនទៅក្នុងអន្ទាក់ការប្រើប្រាស់សារធាតុគីមីដោយខានមិនបាន និងការជំពាក់បំណុលដែលពួកគាត់ទាំងនោះខិតខំប្រឹងប្រែងធ្វើការងារយ៉ាងលំបាកវេទនាដើម្បីសងបំណុលគេទៅវិញ ។

*អត្ថបទដោយលោកស្រី **ម៉ែន វណ្ណារី** មន្ត្រីគំរោងកាត់បន្ថយថ្នាំកសិកម្មនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា*



កសិកររូបនេះធ្លាក់ខ្លួនក្រីក្រដោយសារថ្នាំកសិកម្ម




វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
THE NGO FORUM ON CAMBODIA

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
ការិយាល័យ ផ្ទះលេខ ៩-១១ ទួលទំពូង ១ ភ្នំពេញ
ទូរស័ព្ទលេខ: ០២៣ ២១៤ ៤២៩
ទូរសារលេខ: ០២៣ ៩៩៤ ០៦៣
E-mail: ngoforum@ngoforum.org.kh
Website: www.ngoforum.org.kh